ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ជំនាញកាត់សក់



## បំណិនជីវិតសម្រាប់មធ្យមសិក្សាបឋមភូមិ
## គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា

USAID
ជំនួយពីពលរដ្ឋអាមេរិក

អង្គការអប់រំពិភពលោក
WORLD EDUCATION

ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ
រៀបចំដោយ អង្គការអប់រំពិភពលោក សហការជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣៦៤៣ អយក.ប.ក

# ប្រកាស
# ស្តីពី
# ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
# សៀវភៅ " ជំនាញកាត់សក់ "

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្របក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- យោងគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ២០០៥-២០០៩
- យោងសេចក្តីណែនាំលេខ០៣ អយក. សណន.ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងសំណើរបស់អង្គការអប់រំពិភពលោក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣
- យោងកំណត់ហេតុប្រជុំរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេសនាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៣
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

## សម្រេច

ប្រការ១- អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ " ជំនាញកាត់សក់ " ដែលជាស្នាដៃនិពន្ធនិងរៀបរៀងរបស់អង្គការអប់រំពិភពលោកសហការជាមួយក្រសួងអប់រំ យុវជននិងកីឡា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការបង្រៀន និងរៀនកម្មវិធីបំណិនជីវិតនៅតាមអនុវិទ្យាល័យ ។

ប្រការ២ - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងអង្គការអប់រំពិភពលោក មានភារកិច្ចអនុវត្តប្រកាសនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០១៣

បណ្ឌិត ហង់ ជួន ណារ៉ុន

កន្លែងទទួល :
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- កាលប្បវត្តិ- ឯកសារនៅ.អកស.

## គណៈកម្មការអភិវឌ្ឍសៀវភៅ
## "ជំនាញភាត់សក់"

### គណៈកម្មការនិពន្ធ និងរៀបរៀង

១. លោក ហ៊ិន ស៊ីមហួន
២. លោក អេង សុខ
៣. លោក វីលៀម វ៉ាន់ឌឺវ៉ាល់

### គណៈកម្មការកែសម្រួល

១. លោក ឈុំ វណ្ណធន
២. លោក ប៊ុត សុភាន់
៣. លោក ផុក ចាន់ថុល

### គណៈកម្មការពិនិត្យ

១. លោក ព្រំ វិបុល
២. លោកស្រី យឹម យីហ៊ុប

ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ(USAID)

សហការរៀបចំដោយ
អង្គការអប់រំពិភពលោក និង ក្រសួងអប់រំ យុវជន និងកីឡា

# មាតិកា


អារម្ភកថា........................................ ក

វត្ថុបំណងរួម........................................ ខ

ការត្រៀមលក្ខណៈមុខពេលបង្រៀន........................................ ខ

ខ្លឹមសារសង្ខេប........................................ គ

មេរៀនទី ១: សម្ភារៈកាត់សក់........................................ ១

មេរៀនទី ២: របៀបថែរក្សាសម្ភារៈកាត់សក់........................................ ៦

មេរៀនទី ៣: ការទស្សនាហាងកាត់សក់........................................ ១០

មេរៀនទី ៤: ម៉ូតសក់........................................ ១៣

មេរៀនទី ៥: ម៉ូតសក់ខ្ញុំ ម៉ូតសក់អ្នក........................................ ២០

មេរៀនទី ៦: កន្ត្រៃ និងការកាត់សក់........................................ ២៤

មេរៀនទី ៧: ការថែរក្សាសក់........................................ ៣០

មេរៀនទី ៨: ផលិតផលប្រើជាមួយសក់........................................ ៣៤

មេរៀនទី ៩: ការផ្សព្វផ្សាយ........................................ ៣៨

មេរៀនទី ១០: ការវាយតម្លៃ........................................ ៤០

# អារម្ភកថា

វិស័យអប់រំជាវិស័យគន្លឹះមួយ រួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ពិសេសការអភិវឌ្ឍធនធានមនុស្ស។ ដោយសង្គមជាតិយើងមានការអភិវឌ្ឍលើគ្រប់វិស័យ ការអប់រំក៏ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ប្រកបដោយគុណភាពនិងមានជំនាញខ្ពស់ ដើម្បីបំពេញលើគ្រប់លក្ខខណ្ឌការងារ។

ដើម្បីឆ្លើយតបនឹងតម្រូវការរីកចម្រើននៃទីផ្សារសេរីរបស់សង្គមជាតិ ក្រសួងអប់រំ យុវជននិងកីឡាបានបង្កើតគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ និងគោលនយោបាយអប់រំបំណិនជីវិត សម្រាប់អនុវត្តន៍ នៅតាមសាលារៀនចំណេះទូទៅ។

កម្មវិធីបំណិនជីវិតនៅតាមមូលដ្ឋាន គឺជាស្នូលនៃការបង្កើនគុណភាព និងប្រសិទ្ធភាពក្នុងវិស័យអប់រំ ដែលនឹងផ្តល់ ឲ្យសិស្សនូវចំណេះដឹងមូលដ្ឋានយ៉ាងជ្រៅជ្រះ និងពង្រឹងជំនាញផ្សេងៗដែលមានសារៈសំខាន់សម្រាប់ការស្រូបយកបទពិសោធន៍ល្អៗក្នុងការពង្រឹងចំណេះដឹង និងបំណិន ចាំបាច់សម្រាប់បម្រើជីវភាពរស់នៅប្រចាំថ្ងៃ។

ឯកសារស្តីពី "ជំនាញកាត់សក់" មានគោលបំណងជួយអ្នកសិក្សា ឱ្យទទួលបាននូវចំណេះដឹង ជំនាញ និងបទពិសោធន៍ផ្នែកបំណិនជីវិតងាយៗ ដែលទាក់ទងទៅនឹងជីវិតរស់នៅប្រចាំថ្ងៃ នៅក្នុងសង្គមបច្ចុប្បន្ននេះ។ មុខរបរជាងកាត់សក់នេះ គឺមានលក្ខណៈសាមញ្ញ តែពេញនិយមទាំងនៅក្នុង និងក្រៅប្រទេស ដែលតម្រូវឱ្យមនុស្សគ្រប់រូបត្រូវរៀបចំសក់ របស់ពួកគេឱ្យមានសោភ័ណភាពល្អប្រសើរ ទៅតាមប្រពៃណីវប្បធម៌របស់ប្រទេសនីមួយៗ។ ដូច្នេះមនុស្សដែលមានចំណេះដឹង និងសមត្ថភាពអាចកាត់សក់បាន គឺអាចប្រកបមុខរបរចិញ្ចឹមជីវិតបានល្អប្រសើរ ដូចជនដទៃទៀតផងដែរ ។ ម្យ៉ាងវិញទៀត មុខរបរ កាត់សក់នេះ អាចជួយយុវជន យុវនារី ឱ្យជៀសផុតពីបញ្ហាប្រឈមក្នុងការបោះបង់ការសិក្សា ដែលមិន ឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីអំពីការអប់រំសម្រាប់ទាំងអស់គ្នា។គ្រូត្រូវបានណែនាំយ៉ាងហ្មត់ចត់ ក្នុងការស្វែងរកនូវដៃគូជាមួយនឹងជាងកាត់សក់ ដើម្បីធ្វើការបង្រៀនសិស្សនៅក្នុងក្រុមតូចៗអំពីជំនាញកាត់សក់ ។ ដោយសារតែការសិក្សារបស់សិស្សទាក់ទងទៅ នឹង ជំនាញវិជ្ជាជីវៈ ដូចជាកាត់សក់ គឺចាំបាច់ត្រូវតែធ្វើជាមួយនឹង អ្នកដែលមានជំនាញ។

ដូច្នេះហើយ ទើបវាមានសារៈសំខាន់ណាស់ ដើម្បីធ្វើការអង្កេតមើលដៃគូដែលមាន ព្រមទាំងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងខេត្ត ឬក៏ជាមួយនឹងជាងកាត់សក់ក្នុងតំបន់។ ក្រៅពីការខិតខំប្រឹងប្រែងធ្វើដើម្បីជួយសាលារៀន គ្រូក៏អាចធ្វើការបញ្ជាក់ផងដែរ អំពីផលប្រយោជន៍សម្រាប់ដៃគូ។ ពួកគេទាំងអស់គ្នាទទួលបាននូវឱកាស ដើម្បីផ្សព្វផ្សាយពីខ្លួនរបស់ពួកគេ នៅក្នុងសហគមន៍តាមរយៈសាលា។ នេះក៏ជាលទ្ធផល ដែលអាចនាំឱ្យមានអតិថិជនកាន់តែច្រើន ព្រមទាំងមានចំណូលកាន់តែច្រើនផងដែរ។ ពេលរៀនចប់កម្មវិធីបំណិនជីវិតក្នុងសាលា យើងសង្ឃឹមថាយុជនយុវនារីទាំងអស់នៅ ក្នុងសង្គមបច្ចុប្បន្ននឹងពិចារណាក្នុងការចាប់យកនូវមុខវិជ្ជានេះ សម្រាប់ប្រកបមុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃឱ្យកាន់ តែប្រសើរជាងភាពគ្មានការងារធ្វើ។

## ១. វត្ថុបំណងរួម

បំណិនជីវិត គឺជាបំណិនបញ្ញា បុគ្គលិកលក្ខណៈ អន្តរបុគ្គល និងវិជ្ជាជីវៈដែលអាចជួយដល់ការធ្វើការសម្រេចចិត្ត ការធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព ព្រមទាំងអាចដោះស្រាយ និងគ្រប់គ្រងខ្លួនឯងបាន។ វាគឺជាបំណិន ដែលរួមចំណែកក្នុងការលើកស្ទួយសុខុមាលភាពនិងជីវិតប្រកបដោយផលិតភាព។*(គោលនយោបាយបំណិនជីវិត ២០០៦)*។

ក្រោយពេលរៀនចប់សិស្សមានសមត្ថភាពៈ

- ទទួលបានចំណេះដឹង ស្តីអំពីបំណិនជីវិត ដែលមានសារៈសំខាន់ក្នុងការក្លាយទៅជាជាងកាត់សក់មួយរូប
- កំណត់បានត្រឹមត្រូវពីសម្ភារៈរបស់ជាងកាត់សក់ និងមានចំណេះដឹងមូលដ្ឋាន ព្រមទាំងជំនាញពីរបៀបប្រើប្រាស់សម្ភារៈទាំងអស់នេះ
- រៀនពីរបៀបមានឥរិយាបថល្អចំពោះអតិថិជន
- សិស្សកំណត់ និងប្រើប្រាស់នូវផលិតផលលើសក់ខុសៗគ្នា ដោយអាស្រ័យទៅលើ គោលបំណងនិងផលប៉ះពាល់របស់ពួកគេ។

## ២. ការត្រៀមលក្ខណៈមុនពេលបង្រៀន

ម៉ូឌុលនេះចែកចេញជាច្រើនផ្នែកផ្សេងៗគ្នា ហើយមានគោលបំណងខុសៗគ្នា។ ការត្រៀមលក្ខណៈមុនពេលបង្រៀនសិស្ស ជាដំណាក់កាលត្រៀមរបស់គ្រូ។ ព័ត៌មានទាក់ទងនឹងការបង្រៀន និងរៀន ពិសេសមេរៀន ត្រូវបានគ្រូ ត្រៀមទុកជាមុន។

### • សម្ភារឧបទេស

ផ្នែកនេះផ្តល់នូវសេចក្តីសង្ខេបពីសម្ភារឧបទេស។ ភាគច្រើនជាសម្ភារៈមូលដ្ឋាន ដូចជា ប៊ិក ឬក្រដាស។ សម្ភារៈផ្សេងទៀតនៅក្នុងមេរៀននេះនឹងត្រូវផ្តល់ឱ្យសិស្សសម្រាប់អនុវត្ត តាមរយៈឯកសារសម្រាប់សិស្ស ដែលបានភ្ជាប់នៅក្នុងម៉ូឌុលនេះ។ ពេលខ្លះវាមានការជាន់គ្នាផងដែរ។

### • វត្ថុបំណង

ផ្តល់នូវឃ្លាបញ្ជាក់នូវអ្វីនឹងត្រូវសម្រេចបាន និងវាយតម្លៃនៅខាងចុងមេរៀន។ ឃ្លាទាំងនេះទាក់ទងនឹងគោលដៅរួមរបស់បំណិនជីវិត ដែលបានកំណត់នៅក្នុងគោលការណ៍ណែនាំបំណិនជីវិតនៅមធ្យមសិក្សាបឋម ភូមិ ព្រមទាំងកំណត់នៅក្នុង *បំណិនមូលដ្ឋាន ការសិក្សាជំនួញ បំណិនសេដ្ឋកិច្ចនិងបំណិនអាជីពងាយៗ*។

### • សញ្ញាសម្គាល់សម្រាប់សកម្មភាពនីមួយៗ

ខាងក្រោមនេះ ជាសញ្ញាសម្គាល់សកម្មភាពងាយៗដើម្បីឱ្យគ្រូអនុវត្តបានជោគជ័យក្នុងការបង្រៀន និងរៀន។

✋ ធ្វើសកម្មភាព ៖ គ្រូចាំបាច់ត្រូវធ្វើសកម្មភាពផ្ទាល់ខ្លួន

✎ សរសេរ ៖ ពេលខ្លះត្រូវការឱ្យគ្រូសរសេរនៅលើក្តារខៀន

◈ សួរ ៖ មានសំណួរ ដែលត្រូវសួរទៅកាន់សិស្ស

👄 ពន្យល់ ៖ ពន្យល់ចំណុចសំខាន់ៗ ឬ ប្រាប់សិស្សនៅក្នុងថ្នាក់

● **លំនាំបង្រៀន**

មេរៀននីមួយៗចែកជា ៣ផ្នែក។ ផ្នែកទី១ គឺជាសេចក្តីផ្តើមដែលយើងព្យាយាមផ្សារភ្ជាប់ទៅនឹងចំណេះដឹងដែលសិស្ស មានស្រាប់ ឬរំឭកមេរៀនចាស់។ ផ្នែកទី២ យើងនឹងបង្រៀនសកម្មភាពសំខាន់ៗដោយផ្អែកលើវិធីសាស្ត្រ បង្រៀនបែបការងារគម្រោង( ចុះស្រាវជ្រាវ ប្រមូលព័ត៌មាន សម្ភាស ចងក្រងឯកសារ និងបទបង្ហាញ...។) និងយុទ្ធវិធីបង្រៀនផ្សេងៗទៀត។ នៅផ្នែកទី៣ ដែលជាផ្នែកបញ្ចប់ យើងអាចធានាបានថា រាល់លទ្ធផលនៃការសិក្សារបស់យើង គឺបានឆ្លងកាត់នូវយុទ្ធវិធីខុសៗគ្នាជាច្រើន។

## ៣. ខ្លឹមសារសង្ខេប

ខ្លឹមសារសង្ខេបត្រូវបានផ្តល់ជូនឱ្យគ្រូក្នុងផ្នែកនេះ ដើម្បីជាទុនខ្លះក្នុងការបង្រៀន ហើយក៏ជាសញ្ញាណមួយជាក់លាក់បញ្ជាក់ពីទំនាក់ទំនង និងសារៈសំខាន់រវាងមេរៀននីមួយៗ ។

ខាងក្រោមនេះ គឺជាខ្លឹមសារសង្ខេបរួមទាំង ១០ មេរៀនដែលនៅក្នុងម៉ូឌុលបំណិនជីវិតនេះ ៖

| ចំណងជើងមេរៀន | រយៈពេល | វត្ថុបំណង | ទំព័រ |
|---|---|---|---|
| ១. សម្ភារៈកាត់សក់ | ២ ម៉ោង | នៅក្នុងមេរៀននេះ សិស្សទាំងអស់គ្នានឹងសិក្សាពីឈ្មោះ និងតួនាទីរបស់សម្ភារៈខុសៗគ្នាទាំងអស់ ដែលជាងកាត់សក់ប្រើ។ ពួក គេនឹងធ្វើការអង្កេតមើលនូវសម្ភារៈទាំងនេះ ហើយ ធ្វើបទ បង្ហាញគោល បំណងរបស់ពួកគេ ទៅមិត្តរួមថ្នាក់ ដែលនៅក្នុងក្រុម។ | ១ |
| ២. របៀបថែរក្សាសម្ភារៈកាត់សក់ | ២ ម៉ោង | ចំពោះសប្តាហ៍នេះ សិស្សទាំងអស់គ្នានឹងធ្វើការសិក្សា បន្ថែម អំពីសម្ភារៈទាំងនោះ និងវិធីក្នុងការថែទាំពួកវា។ ប្រធានបទផ្សេងទៀត គឺនិយាយពីរបៀបសម្តែងឥរិយាបថ ចំពោះអតិថិជន។ ការរៀបចំជំនាញ និងភាពចេះបត់បែន ក៏នឹងត្រូវបានអនុវត្តផងដែរ។ | ៦ |
| ៣. ការទស្សនាហាងកាត់សក់ | ២ ម៉ោង | យើងនឹងរៀបចំការធ្វើទស្សនកិច្ចសិក្សាមួយ ទៅជួបនឹង ជាងកាត់សក់ ដើម្បីគ្រូតពិនិត្យមើលការរំពឹងរបស់ ពួកយើង និងដើម្បីទទួលបាននូវការបង្ហាញពីជីវិតពិតមួយ នៃការកាត់សក់។ សិស្សទាំងអស់គ្នានឹងធ្វើការសម្ភាសជាងកាត់សក់អំពីការងាររបស់ពួកគេ។ | ១០ |
| ៤. ម៉ូតសក់ | ២ ម៉ោង | សិស្សនឹងកំណត់បានពីម៉ូតសក់ខុសៗគ្នា ដែលម៉ូតសក់ទាំងអស់នោះ ឆ្លុះបញ្ចាំងពីបុគ្គលិកលក្ខណៈ។ យើងក៏នឹងធ្វើការសិក្សាអំពីភាពផ្សេងគ្នា និង ដែនកំណត់របស់វាដែរ។ នៅចុងបញ្ចប់សិស្សនឹងជ្រើសរើសបាននូវម៉ូតសក់មួយ ប្រកបទៅដោយការច្នៃប្រឌិត ដែលពួកគេគិតថាសមស្រប ទៅនឹងពួកគេផងដែរ។ | ១៣ |
| ៥. ម៉ូតសក់ខ្ញុំ ម៉ូតសក់អ្នក | ២ ម៉ោង | នៅក្នុងសប្តាហ៍នេះសិស្សនឹងធ្វើបទបង្ហាញពីម៉ូតសក់ផ្ទាល់ ខ្លួនរបស់ពួកគេ និងធ្វើការឆ្លុះបញ្ចាំងមកលើគំនិត របស់អ្នកដទៃផងដែរ។ យើងនឹងអនុវត្តការធ្វើបែបនេះតាមរយៈវិធី ក្នុងការផ្តល់ជាមតិយោបល់ និងការសរសើរ។ | ២០ |

| | | | |
|---|---|---|---|
| ៦. កន្ត្រៃ និងការកាត់សក់ | ២ ម៉ោង | យើងនឹងនាំគ្នាត្រឡប់ទៅកាន់ហាងកាត់សក់។ ប្រសិន ជាអាច ពួកយើងទាំងអស់គ្នាព្រមទាំងជាងកាត់សក់ នឹងធ្វើការសិក្សាអំពីការរៀបចំកាត់សក់ ដោយប្រើប្រាស់ សម្លៀកបំពាក់ កៅអី និងបរិស្ថាន។ | ២៤ |
| ៧. ការថែរក្សាសក់ | ២ ម៉ោង | យើងនឹងសិក្សាអំពីការសម្អាតសក់របស់យើង និងរៀននូវអ្វី ថ្មីៗអំពីការសម្អាតសក់នោះ។ ឧទាហរណ៍មួយ នឹងបង្ហាញពីការសម្អាតសក់របស់យើងដោយម្សៅ ក៏ប៉ុន្តែការអនុវត្តដ៏ សាមញ្ញមួយ គឺធ្វើការសម្អាតសក់ដោយប្រើ សាប៊ូ។ មានកំហុសជាច្រើន ដែលបង្កើតចេញមកពី ការធ្វើបែបនោះ ហើយសិស្សក៏នឹងសិក្សាពីវិធីត្រឹមត្រូវដើម្បីធ្វើវាផងដែរ។ | ៣០ |
| ៨. ផលិតផលប្រើជាមួយសក់ | ២ ម៉ោង | តាមរយៈកិច្ចការផ្ទះ សិស្សទាំងអស់គ្នាបានធ្វើការពិនិត្យមើល លើកដំបូង អំពីផលិតផលប្រើលើសក់ខុសៗគ្នាជាច្រើន។ យើងនឹង ព ង្រីកចំណេះដឹងរបស់ពួកយើងអំពីចំណុចទាំងអស់នេះ ហើយនឹងបែងចែកផលិតផលទៅតាមផ្នែកខុសៗគ្នាជាច្រើន។ | ៣៤ |
| ៩. ការផ្សព្វផ្សាយ | ២ ម៉ោង | តាមរយៈការអង្កេតមួយ សិស្សទាំងអស់គ្នានឹងធ្វើការបង្ហាញមួយស្តីអំពី ការប្រៀបធៀបគ្នារវាងផលិតផល២ នៅក្នុងផ្នែក តែមួយ។ ពួកគេនឹងធ្វើការវិនិច្ឆ័យ ដោយការអាន ការស្ទង់មើល និងការប្រឡង។ នេះគឺជាលទ្ធផលនៅក្នុងការធ្វើបទ បង្ហាញព័ត៌មាន ចំពោះមិត្តរួមថ្នាក់របស់ពួកគេ។ | ៣៨ |
| ១០. ការវាយតម្លៃ | ២ ម៉ោង | នៅមេរៀនចុងក្រោយនៃឯកសារនេះ គឺនិយាយអំពីការវាយតម្លៃចំណេះដឹងរបស់សិស្សនៅក្នុងការប្រឡងសរសេរ។ ការប្រឡងនេះ គឺជាផ្នែកមួយនៃការវាយតម្លៃនីតិវិធីនៅក្នុង ឯកសារបំណិនជីវិត និងមានវិធីដែលប្រកបទៅដោយការច្នៃប្រឌិត នៃការអនុវត្តចំណេះដឹងរបស់សិស្ស។ | ៤០ |

## ៤. ការវាយតម្លៃ

ការវាយតម្លៃមាន២ផ្នែកសំខាន់ៗ។ មួយផ្នែកជាការវាយតម្លៃនៅចុងបញ្ចប់នៃម៉ូឌុលនីមួយៗ និងជាវិញ្ញាសាសរសេរ ដែលយើងត្រូវបញ្ចូលនៅផ្នែកខាងចុងម៉ូឌុល ។ ផ្នែកមួយទៀត ជាការវាយតម្លៃទៅលើឥរិយាបថសិស្ស ដោយគ្រូជាអ្នកសង្កេត ផ្ទាល់រៀងរាល់ថ្ងៃ ហើយដាក់ពិន្ទុ។ វិធីវាយតម្លៃទាំងពីរចំណុចនេះមានសារៈសំខាន់ក្នុងការវាស់ចំណេះដឹង និងឥរិយាបថរបស់សិស្សម្នាក់ៗ ។ ចំពោះការវាយតម្លៃសិស្សនេះ យើងគិតពិន្ទុ ៥០ ស្មើទៅនឹងមុខវិជ្ជាមួយចំនួនផងដែរ គឺយើងឱ្យពិន្ទុ ៣៥ ទៅលើឥរិយាបថ និងពិន្ទុ ១៥ ទៅលើវិញ្ញាសាសរសេរ។

នៅតាមមេរៀននីមួយៗ គ្រូទុកពេលឱ្យសិស្សពិភាក្សាក្រុមតូចឱ្យបានច្រើន នៃចំណុចសំខាន់ៗនៅពាក់កណ្តាលមេរៀននីមួយៗ។ កំឡុងពេលសិស្សពិភាក្សាក្រុមតូច ជាពេលវេលាដែលគ្រូអាចសង្កេតឥរិយាបថសិស្សក្នុងការដាក់ពិន្ទុ។ ជាការល្អគ្រូគួរដាក់ពិន្ទុឥរិយាបងសិស្សចាប់ពីមេរៀនទី ៦ តទៅ។

## ៥. ឯកសារបន្ថែម

ផ្នែកនេះផ្តល់នូវព័ត៌មានរួមសម្រាប់គ្រូប្រើប្រាស់ រួមទាំងផ្ទាំងរូបភាពសម្រាប់គ្រូប្រើប្រាស់នៅក្នុងមេរៀននេះ។

# មេរៀនទី ១: សម្ភារៈកាត់សក់

🕑 រយៈពេលបង្រៀនៈ ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- សម្ភារៈពិតៗរបស់ជាងកាត់សក់
- ផ្ទាំងរូបភាពនៃសម្ភារៈរបស់ជាងកាត់សក់
- ក្រដាស ហ្វឺត ស្កុត

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- កំណត់បានយ៉ាងច្បាស់ពីឈ្មោះសម្ភារៈកាត់សក់
- ពន្យល់ពីការរៀបចំហាងការកាត់សក់ ដែលមានសុវត្ថិភាព

## សេចក្តីផ្តើម

🕑 ១៥ នាទី

✋ យកកន្ត្រៃ ហើយលើកបង្ហាញសិស្សទាំងអស់

◈ តើនរណាដឹងថារបស់នេះជាអ្វី?

តើអ្នកអាចយកវាទៅធ្វើអ្វីបាន?

👄 បន្ទាប់ពីសិស្សមួយចំនួនបានផ្តល់នូវចម្លើយចំពោះសំណួរ ចូរប្រាប់ពួកគេថា អ្នកទាំងអស់គ្នា នឹងប្រើប្រាស់កន្ត្រៃនេះដើម្បីកាត់សក់របស់ពួកគេ និងសិស្សដទៃៗទៀត ប្រសិនបើពួកគេ អនុញ្ញាតឱ្យអ្នកធ្វើដូច្នោះ។

សិស្សទាំងអស់នោះប្រហែលជាមិនអនុញ្ញាត ឱ្យអ្នកកាត់សក់របស់ពួកគេនោះទេ។ ចូរសួរពួកគេថា៖ ហេតុអ្វី?

ដើម្បីកាត់សក់របស់នរណាម្នាក់ អ្នកទាំងអស់គ្នាចាំបាច់ត្រូវតែមានជំនាញ និងចំណេះដឹង ខាងកាត់សក់។

ឯកសារនេះ យើងនឹងសិក្សាអំពីការកាត់សក់។ ជាដំបូងខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នាគិតអំពីអ្វី ដែលអ្នកបានដឹងអំពីសក់ និងជាងកាត់សក់។




ខ្ញុំសូមណែនាំដល់អ្នកទាំងអស់គ្នា នេះគឺជារូបភាពដែលនឹងជួយយើងក្នុងការសិក្សាមេរៀននេះ។ យើងទាំងអស់គ្នានឹងកាត់សក់ឱ្យគាត់ឱ្យបានស្អាត។ គ្រប់គ្នាដែលដឹងពីរឿងអ្វីមួយទាក់ទងទៅនឹងជាងកាត់សក់ ឬក៏ការកាត់សក់ អាចមក ខាងមុខបាន ហើយគូរនូវរូបភាពមួយដែលពាក់ព័ន្ធនឹងសក់ ព្រមទាំងសរសេរនូវពាក្យនោះផងដែរ។

ខ្ញុំបានយកប្រអប់មួយដែលមានសម្ភារៈខុសៗគ្នាជាច្រើនទៀតនៅក្នុងប្រអប់នោះ។ សម្ភារៈទាំងអស់ នេះ គឺត្រូវបានប្រើប្រាស់ដោយជាងកាត់សក់។ ខ្ញុំនឹងបង្ហាញសម្ភារៈទាំងនោះទៅអ្នកទាំងអស់គ្នា ហើយប្រសិនបើអ្នកស្គាល់ឈ្មោះសម្ភារៈទាំងនោះ អ្នកអាចសរសេរឈ្មោះទាំងនោះក្នុងសៀវភៅរបស់អ្នក។

បង្ហាញសម្ភារៈទាំងអស់ម្តងមួយៗ ប៉ុន្តែកុំប្រាប់ពីឈ្មោះរបស់វា។ ឱ្យសិស្សសរសេរឈ្មោះសម្ភារៈទាំងនោះនៅក្នុងសៀវភៅរបស់ពួកគេ។បន្ទាប់ពីអ្នកបានបង្ហាញនូវសម្ភារៈទាំងអស់នោះរួចរាល់ហើយ ចូរដាក់វានៅខាងលើតុពីមុខមិត្តរួមថ្នាក់ទាំងអស់គ្នា។

ប្រសិនបើអ្នកទាំងអស់គ្នាស្គាល់ឈ្មោះសម្ភារៈទាំងអស់នេះ អ្នកអាចឡើងមកខាងមុខ ហើយសរសេរវានៅលើក្រដាសតូចមួយ ដែលយើងនឹងដាក់វានៅក្បែរសម្ភារៈនោះ។ មើលសេចក្តីណែនាំគ្រូសម្រាប់ព័ត៌មានបន្ថែមអំពីចំណុចទាំងអស់នេះ។

តើអ្នកទាំងអស់គ្នាដឹងទេថា ជាងកាត់សក់ប្រើកាំបិតកោរសម្រាបធ្វើអ្វី? តើវាមានអ្វីសំខាន់ទាក់ទងទៅនឹងកាំបិតកោរនេះ? (វាគឺត្រូវបានប្រើសម្រាប់កោរ ហើយវាចាំបាច់ត្រូវតែមុត)។

យើងនឹងបន្តគិតអំពីសម្ភារៈដទៃទៀត។ អ្នកទាំងអស់គ្នាអាចបង្កើតជាក្រុម ដែលមានគ្នា ៣ ទៅ ៤នាក់ ហើយធ្វើការជ្រើសរើសយកសម្ភារៈមួយក្នុងចំណោមសម្ភារៈទាំងអស់ដែលដាក់នៅលើតុ។ បន្ទាប់មកខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នាបង្កើតជាសៀវភៅមួយ ស្តីអំពីឧបករណ៍នេះ។ អ្នកអាចយកក្រដាសមួយសន្លឹក ហើយគូរឧបករណ៍នោះ បន្ទាប់មកសរសេរ៖

- ឈ្មោះ
- របៀបប្រើ
- របៀបរៀបចំ
- សារៈសំខាន់

អ្នកទាំងអស់គ្នាអាចធ្វើការពិភាក្សាគ្នាជាមួយនឹងក្រុមរបស់អ្នកបានលើគ្រប់ផ្នែកនូវអ្វីខ្លះ ដែលអាចសរសេរ ឬកត់ត្រា។ ក្នុងរយៈពេល១០នាទី។ បន្ទាប់មកបង្ហាញនូវសន្លឹកប័ណ្ណតូចៗ ដោយដាក់នឹង ព្យួរវានៅលើជញ្ជាំងតាមក្រុមនីមួយៗ។

នៅពេលដែលសិស្សទាំងអស់គ្នា កំពុងពិភាក្សាអំពីទិដ្ឋភាពសំខាន់ៗ និងអ្វីដែលត្រូវកត់ត្រា គ្រូដើរពិនិត្យតាមក្រុម ហើយឱ្យជាដំបូន្មានមួយចំនួន។

អ្នកទាំងអស់គ្នាអាចឡើងមកខាងមុខជាមួយនឹងក្រុមរបស់អ្នក ហើយធ្វើការពន្យល់ខ្លីៗ អំពីអ្វី ដែលអ្នកបានសរសេរ។

**សកម្មភាពសំខាន់។** ៦០ នាទី

នៅពេលដែលអ្នកទៅហាងកាត់សក់ តើអ្វីដែលអ្នកគិតថាមានសារៈសំខាន់?

រៀបចំការសន្ទនាជាក្រុមតូចមួយ អំពីបទពិសោធនៅឯហាងកាត់សក់។ តើមាននរណាម្នាក់ដែលអាចប្រាប់ខ្ញុំអំពីអ្វីដែលកើតឡើងជាធម្មតានៅទីនោះ ឬក៏អ្វីដែលអ្នកគិតឃើញថា សំខាន់ នៅពេលដែលអ្នក គឺជាជាងកាត់សក់មួយរូប?

ក្នុងការចាប់ផ្តើមជាជាងកាត់សក់មួយរូប គឺមានន័យថា អ្នកត្រូវតែរៀបចំកន្លែងរបស់អ្នកឱ្យ បានល្អ។ អតិថិជនរបស់អ្នកត្រូវតែអង្គុយឱ្យបានស្រួល ហើយអ្នកត្រូវតែអាចមើលឃើញ នូវការងារដែលបានធ្វើរួច។ ចំពោះទីកន្លែងក៏ត្រូវឱ្យគេមើលមកឃើញស្អាត និងសមរម្យ ហើយអនាម័យ គឺជាអ្វីដែលសំខាន់នៅពេលដែលអ្នកក្លាយជាជាងកាត់សក់។

តើអ្វីផ្សេងទៀត ដែលមានសារៈសំខាន់ នៅពេលដែលអ្នកធ្វើការនៅក្នុងហាងកាត់សក់?

អ្នកទាំងអស់គ្នាក៏អាចធ្វើការពិភាក្សាគ្នាអំពីចំណុចទាំងនេះ ជាមួយនឹងអ្នកដែលអង្គុយនៅជិត អ្នក។ អ្នកមានពេល ៣នាទី ដើម្បីរកនឹកនូវអ្វីដែលសំខាន់ចំនួន១០ អំពីការរៀបចំកន្លែង និង អាកប្បកិរិយារបស់អ្នក។

ឱ្យសិស្សទាំងអស់ធ្វើការគិតអំពីវា បន្ទាប់មកទៀតចែករំលែកនូវគំនិតរបស់ពួកគេ ដោយ ផ្ទាល់។ ស្នើសុំឱ្យសិស្សពីរនាក់ធ្វើការជាដៃគូ ចាប់ផ្តើមធ្វើការបង្ហាញនូវអ្វី ដែលពួកគេបានស្វែងរកឃើញថា មានសារៈសំខាន់ ហើយឱ្យសិស្សដទៃទៀតធ្វើការត្រួតពិនិត្យមើលអ្វី ដែលបានបង្ហាញជាមួយនឹងបញ្ជីរបស់ពួកគេ។ បន្ទាប់ពីដៃគូនោះបានបញ្ចប់ ឱ្យសិស្សដទៃៗទៀតធ្វើការបន្ថែមទៅក្នុងបញ្ជី។

ចំពោះចម្លើយដែលអាចមាន គឺអាចរួមបញ្ចូលនូវ ៖ កន្លែងស្អាត ឧបករណ៍ស្អាត គុដែលបានសំអាតត្រឹមត្រូវ កន្សែងសាប៊ូ ម្សៅក្រែមសម្រាប់កោរ ត្រូវមានកង្ហារ/ម៉ាស៊ីនត្រជាក់ សម្លៀកបំពាក់ស្អាតសម្រាប់ជាងកាត់សក់ កំណាត់ទ្រនាប់ដៃត្រូវស្អាត មានទឹកសម្រាប់ផឹក ប្រហែលជាអាចមាននូវចម្រៀងកំដរ និងបង្កើតតារាងពេល វេលាមួយសម្រាប់អតិថិជន។

ឥឡូវយើងទាំងអស់គ្នាបានសិក្សាពីឧបករណ៍ និងលក្ខខណ្ឌជាច្រើនដើម្បីចាប់ផ្តើម បង្កើតជា ហាងកាត់សក់មួយ។ ថ្ងៃនេះអ្នកទាំងអស់គ្នានឹងចាប់ផ្តើមបង្កើតហាងមួយនៅលើក្រដាស។ កិច្ចការបន្ទាប់ គឺត្រូវនាំគ្នាគូរផ្ទៃកខាងក្នុងរបស់ហាងកាត់សក់ ហើយនេះអាចជាគំនូរមួយដោយនៅពីក្រោម គំនូរនេះ អ្នកនឹងត្រូវធ្វើការពន្យល់ពីអ្វីដែលអ្នកបានគូរ និងមូលហេតុដែលអ្នកដាក់វានៅទីនោះ។

ផ្តល់ជាឧទាហរណ៍គំរូមួយ ដោយធ្វើការគូររូបកញ្ចក់មួយ និងកៅអីមួយឱ្យនៅជិតគ្នា ហើយសរសេរពីខាងក្រោម៖

១. កញ្ចក់ និងកៅអី គឺនៅជិតគ្នា ដូច្នេះភ្ញៀវអាចមើលឃើញសក់របស់ពួកគេ។

២. ចំពោះនាឡិកា គឺភ្ញៀវអាចមើលម៉ោងឃើញ។






✋ ក្រដាសធំទទេស្អាត ដែលជាឯកសារសម្រាប់សិស្ស ហើយប្រសិនជាអាច គឺទំហំA4។ ឱ្យសិស្សទាំងអស់ធ្វើការនៅក្នុងក្រុមដដែល នៅពេលកំពុងធ្វើការត្រូវនឹករកគំនិត។ ពួកគេទាំងអស់គ្នាមានរយៈពេល២០នាទី ក្នុងការនឹករកនូវគំនិត ព្រមទាំងការរចនាម៉ូតដ៏ល្អ និង មានប្រសិទ្ធភាពមួយសម្រាប់ហាងកាត់សក់របស់ពួកគេម្នាក់ៗ។

នៅចន្លោះពេលនោះផងដែរ គ្រូអាចដើរមើលតាមក្រុមដើម្បីព្យាយាមជំរុញសិស្សឱ្យនាំគ្នាបង្កើតនូវហាងកាត់សក់មួយ ដែលមើលទៅល្អ និងមានប្រសិទ្ធភាព។ ប្រសិនបើអាច ពួកគេអាចគូរ ដោយប្រើខ្មៅដៃពណ៌ ដើម្បីធ្វើឱ្យគំនូរកាន់តែមើលឃើញច្បាស់ល្អ។ បន្ទាប់ពីរយៈពេល២០នាទី ពួកគេអាចធ្វើ ការពន្យល់ ៖

👄 រាល់ក្រុមទាំងអស់ ត្រូវឱ្យសមាជិកក្រុមរបស់ពួកគេចំនួន២នាក់ ដើម្បីទៅមើលគំនូរហាងដទៃៗទៀត ។ នៅពេលដែលពួកគេទៅមើលក្រុមដទៃ ពួកគេត្រូវតែធ្វើការពន្យល់អំពីហាងរបស់ពួកគេ ហើយគ្រូក៏អាចសួរនូវសំណួរជាច្រើន ឬផ្តល់ជាមតិវិជ្ជមានមួយចំនួន។

❓ តើរូបគំនូរហាងណាមួយ ដែលអ្នកចូលចិត្ត ហើយហេតុអ្វី?

## បញ្ចប់មេរៀន

🕒 ១៥ នាទី

👄 ខ្ញុំនឹងអ្នកណាម្នាក់ក្នុងចំណោមអ្នកទាំងអស់គ្នា ធ្វើការបង្ហាញនូវល្បែងមួយ។ សិស្សម្នាក់នោះ នឹងត្រូវបិទភ្នែក បន្ទាប់មកទៀត ខ្ញុំនឹងផ្តល់ឱ្យនូវឧបករណ៍មួយ ដែលជាងកាត់ សក់ប្រើប្រាស់ ឬជាឧបករណ៍មួយដែលមាននៅក្នុងហាងកាត់សក់។ សិស្សម្នាក់នោះ ត្រូវទាយថាតើវាជាឧបករណ៍ ឬសម្ភារៈអ្វី ដោយគ្រាន់តែប៉ះ និងគិតឱ្យបានត្រឹមត្រូវ។

✋ បិទភ្នែកសិស្សពីរឬបីនាក់ ហើយឱ្យសិស្សដទៃទៀតធ្វើការជ្រើសរើសយកនូវឧបករណ៍មួយ ហើយត្រូវដាក់ថ្នមៗនៅលើដៃរបស់សិស្សដែលត្រូវបានគេបិទភ្នែកនោះ។ អ្នកត្រូវធ្វើការ សរសើរសិស្សទៅលើការខិតខំប្រឹងប្រែងរបស់ពួកគេ បើទោះបីពួកគេទាយខុសក៏ដោយ។ ការធ្វើបែបនេះ នឹងបង្កើតបរិយាកាសវិជ្ជមានមួយ ដែលនឹងធ្វើឱ្យគ្រប់គ្នាមានអារម្មណ៍ជឿជាក់ក្នុងការលេងល្បែងនៅពេលក្រោយៗទៀត។

# សេចក្តីណែនាំគ្រូ

តើអ្វីខ្លះដែលជាសម្ភារៈរបស់ជាងកាត់សក់?

សម្ភារៈជាងកាត់សក់មានដូចជា ៖ កន្ត្រៃគុងដឺ-កន្ត្រៃច្រិប-កន្ត្រៃសាប់-កំណាត់រុំ-កំណាត់ ទ្រនាប់-ដងឡាម-ផ្លែឡាម-ម៉ាស់-ដង្កៀប-កន្សែង-ម្សៅ-កញ្ចក់-ជក់បោសសក់-ក្រាសធំ តូច -ដបបាញ់ទឹក-កៅអី-រូបប៉ូស្ទ័រម៉ូតសក់។



*រូបភាពសម្ភារៈ របស់ ជាងកាត់សក់*

# មេរៀនទី ២: របៀបថែរក្សាសម្ភារៈកាត់សក់

🕑 រយៈពេលបង្រៀនៈ ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)។

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- សិស្សមានសៀវភៅ ប៊ិក និងក្រដាស
- ប្រេងលាបសក់ ជក់បោសសក់ កញ្ចក់ កន្រ្តៃគុងដីសំលៀងជាមួយនឹងកាកសី កន្រ្តៃសាប់ កន្រ្តៃច្រិប កាំបិតកោរ ដបបាញ់ទឹក កំណាត់រុំ ក្រាសតូច ធំ។ល។
- ថតចម្លងឯកសារសម្រាប់សិស្ស។

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- ប្រាប់ពីវិធីថែរក្សាសម្ភារៈបន្ទាប់ពីប្រើរួច ដោយជុសសម្អាត និងដាក់ប្រេងកន្ត្រៃគ្រប់ប្រភេទ ដើម្បីការពារកុំឱ្យមានធូលី និងច្រែះបានត្រឹមត្រូវ
- ពន្យល់ពីរបៀបបញ្ចូលកាំបិតក្នុងស្រោមបិទ ឬគម្រប
- ពន្យល់ពីរបៀបខ្លះៗនៃការសំលៀងកន្ត្រៃ ។

**សេចក្តីផ្តើម** 🕑 ១៥ នាទី

⊘ តើអ្នកអាចចែករំលែកនូវអ្វីមួយ ដែលអ្នកបានរៀនពីមេរៀនមុនបានឬទេ?

👄 មេរៀននេះយើងនឹងធ្វើការសិក្សាពីរបៀបប្រើប្រាស់សម្ភារៈកាត់សក់។ ជាដំបូង យើងនឹងនាំគ្នាលេងល្បែងមួយជាមួយនឹងសម្ភារៈទាំងនោះ។ ខ្ញុំត្រូវការនរណាម្នាក់ ដើម្បីឡើងមកខាងមុខ ហើយធ្វើជាកំពុងប្រើប្រាស់ឧបករណ៍មួយ ពីមេរៀនទីមួយ។ ប្រសិនបើ នរណាម្នាក់ដឹងថា ឧបករណ៍នោះជាអ្វី អ្នកអាចនិយាយប្រាប់បាន។

ប្រសិនបើឆ្លើយត្រូវ បុគ្គលនោះអាចឈរនៅខាងមុខមិត្តរួមថ្នាក់ទាំងអស់ ហើយធ្វើការប្រើប្រាស់សម្ភារៈដទៃផ្សេងមួយទៀត។

✋ លេងល្បែងនោះពីរបីដង ដើម្បីប្រាកដថា សិស្សទាំងអស់គ្នាស្គាល់ពីសម្ភារៈមូលដ្ឋានជាច្រើន ដែលមានដូចជា ជក់ កំណាត់រុំ កន្ត្រៃសាប់ មេ្សៅ កន្សែង កៅអី កាំបិតកោរ។

👄 នៅពេលប្រើប្រាស់ឧបករណ៍ទាំងអស់នេះ យើងទាំងអស់គ្នាត្រូវដឹងថា យើងត្រូវថែរក្សាវាឱ្យស្អាត ប៉ុន្តែតើយើងធ្វើបានដោយវិធីណា? ហើយប្រសិនបើវាត្រូវបានសម្អាត តើយើងត្រូវថែរក្សាវាដោយវិធីណា?

បង្ហាញពីវិធីសាស្ត្រសម្អាតមូលដ្ឋាន នៃឧបករណ៍ខុសៗគ្នាទាំងនោះ។

កន្ត្រៃ: ជូតវាឱ្យស្អាតដោយប្រើជក់ បន្ទាប់ពីកាត់សក់រួច ហើយប្រើប្រេងលាបសក់ ដើម្បី ធ្វើឱ្យវារលោង និងការពារវាមិនឱ្យច្រែះ។ វិធីទី៣នៃការថែរក្សាវាឱ្យស្អាត គឺត្រូវដាក់វានៅក្នុង កាបូប នៅពេលអ្នកមិនប្រើប្រាស់វា។

កាំបិតកោរៈ ធ្វើការសម្អាតដោយប្រើទឹក នៅគ្រប់ពេលបន្ទាប់ពីអ្នកយកទៅប្រើប្រាស់។ ដោយសារតែវាងាយ នឹងធ្វើឱ្យមុតមនុស្ស ដូច្នេះជាការសំខាន់ណាស់ក្នុងការត្រួតពិនិត្យមើល វាផងដែរ។ ត្រូវដាកើកាំនិតកោរនៅក្នុងស្រោម។

ចំពោះឧបករណ៍ទាំងអស់នោះត្រូវតែចងចាំថា អ្នកទាំងអស់គ្នាមិនអាចប្រើប្រាស់វានៅពេលដែលវាមានច្រែះឡើយ ព្រោះវាអាចបណ្តាលឱ្យអ្នកមានជំងឺបាន។

## សកម្មភាពសំខាន់។

៦០ នាទី

ល្អណាស់ ឥឡូវនេះយើងបានរៀបពីអ្វីដែលយើងត្រូវការនៅក្នុងហាងកាត់សក់ ហើយក៏បានដឹងពីវិធីក្នុងការសម្អាតឧបករណ៍មួយចំនួន ។ ខ្ញុំគិតថា វាដល់ពេលដែលត្រូវធ្វើការអនុវត្ត ហើយ។ នៅថ្ងៃនេះ យើងនឹងព្យាយាមស្វែងរកចម្លើយចំពោះសំណួរៈ

តើការរាក់ទាក់ចំពោះអតិថិជន គឺជាអ្វី?

យើងនឹងនាំគ្នាធ្វើការសិក្សាសំណួរនេះតាមរយៈករណីសិក្សាតូចមួយ។ យើងបែងចែកសិស្សក្នុងថ្នាក់របស់យើងទៅជាក្រុមតូចៗ ដែលមានគ្នា៦នាក់។ រាល់ក្រុមទាំងអស់ទទួលបានប័ណ្ណ មួយឈុតសម្រាប់សម្តែងតួ។ សិស្ស២នាក់នឹងធ្វើការអនុវត្តជាមួយនឹងប័ណ្ណទាំងនេះ។

កិច្ចការសម្រាប់ជាងកាត់សក់ គឺត្រូវមានភាពរួសរាយ រាក់ទាក់ចំពោះអតិថិជន។ ចំណែកឯអតិថិជនត្រូវសម្តែងតាមប័ណ្ណដែលចែកឱ្យ។ បន្ទាប់ពីការសម្តែងរួចរាល់ ហើយក្រុមដែលនៅសល់ ធ្វើការផ្តល់មតិរិះគន់ខ្លី ដោយអនុវត្តតាមសំណួរខាងក្រោមៈ

តើមធ្យោបាយបែបណា ដែលជាងកាត់សក់ត្រូវរួសរាយរាក់ទាក់ចំពោះអតិថិជន?

តើចំណុចអ្វីខ្លះដែលគាត់/នាងអាចគួរធ្វើការកែលម្អនៅពេលក្រោយ?

ផ្តល់ឯកសារសម្រាប់សិស្ស(២.១) ឱ្យទៅក្រុមសិស្សទាំងអស់។ នៅពេលដែលសិស្សទាំងអស់គ្នា កំពុងធ្វើការសម្តែង គ្រូដើរជុំវិញ ហើយបំពេញនៅក្នុងក្រដាសវាយតម្លៃ ពីការសិក្សារបស់សិស្ស។ បន្ទាប់ពីរយៈពេល ៣០ នាទី ឱ្យសិស្សទាំងអស់ត្រឡប់មក កាន់កន្លែងរបស់ពួកគេវិញ។

សួរអំពីលទ្ធផលរបស់ពួកគេ និងចម្លើយចំពោះសំណួរដែលសួរថា តើការរួសរាយរាក់ទាក់ ចំពោះអតិថិជនមានន័យដូចម្តេច?

ការរួសរាយរាក់ទាក់ចំពោះអតិថិជន គឺមិនមានន័យថា អ្នកតែងតែយល់ស្របជាមួយនឹង អតិថិជនឬក៏អ្នកតែងតែនិយាយពាក្យថា "បាទ" ឬ "ខ្ញុំមាន" ឬ "ខ្ញុំអាច"។អ្នកត្រូវតែមានភាពស្មោះត្រង់ចំពោះការទទួលខុសត្រូវ ថែមទាំងទន់ភ្លន់នៅក្នុងការឆ្លើយតប របស់អ្នក។

តើនរណា ដែលបានឃើញនូវឧទាហរណ៍ល្អៗរបស់ជាងកាត់សក់ដែលស្មោះត្រង់ ថែមទាំងជាជាងកាត់សក់ដែលស្លូតបូតឬទេ?

**បញ្ចប់មេរៀន** ១៥ នាទី

យើងទាំងអស់គ្នា បានអនុវត្តក្នុងការធ្វើជាជាងកាត់សក់ ក៏ប៉ុន្តែបើក្លាយទៅជាជាងកាត់សក់ពិតមួយរូប គឺមានលក្ខណៈពិបាកណាស់។ នៅសប្តាហ៍ក្រោយយើងនឹងមានគម្រោងទៅទស្សនា ហាងកាត់សក់មួយ។

នៅផ្នែកចុងក្រោយនៃមេរៀននេះ យើងនឹងរៀបចំនូវការធ្វើដំណើរនេះ។ (មើលកំណត់ត្រារបស់គ្រូ) យើងនឹងត្រូវការនរណាម្នាក់ ដែលត្រូវការកាត់សក់ ដូច្នេះជាង  កាត់សក់អាចធ្វើការបង្ហាញពីរបៀបដែលគាត់ធ្វើការងារ។

តើនរណាដែលស្ម័គ្រចិត្ត ដើម្បីឱ្យគាត់កាត់សក់នៅក្នុងសប្តាហ៍ក្រោយ?

សិស្សនីមួយៗ នឹងត្រូវរកនឹកសំណួរយ៉ាងហោចណាស់ឱ្យបាន៥ ដែលអ្នកនឹងសួរជាងកាត់ សក់ ។ អ្នកក៏ចាំបាច់ត្រូវគិតឱ្យបានពីរចំណុច ដែលអ្នកចង់ដឹងដោយការអង្កេតមើលហាង ឬក៏នៅជុំវិញ។ សំណួរ និងការសង្កេតអាចត្រូវបានកត់ត្រានៅក្នុងសៀវភៅរបស់ អ្នក។ ប្រសិនបើនៅសល់ពេល អ្នកអាចធ្វើការសម្តែងតួម្តងទៀត ។

សិស្សអាចប្តូរការសម្តែងរបស់ពួកគេបាន។ ឧទាហរណ៍ ៖ ពួកគេអាចងងុយដេក ចាប់ ផ្តើមច្រៀងចម្រៀង ឬចាប់ផ្តើមយំ។ វាអាស្រ័យទៅលើជាងកាត់សក់ ដែលត្រូវធ្វើឱ្យស្របទៅតាមច្បាប់រួសរាយរាក់ទាក់របស់ជាងកាត់សក់ចំពោះអតិថិជន។ នេះ មានន័យថា អតិថិជន អាចធ្វើអ្វីដែលកំប្លែង ប៉ុន្តែកុំខឹង ឬអន់ចិត្ត។

## សេចក្តីណែនាំគ្រូ

● ការធ្វើទស្សនកិច្ចសិក្សាមួយទៅកាន់ហាងកាត់សក់ គឺជាការផ្លាស់ប្តូរដ៏ល្អមួយសម្រាប់ជាង កាត់សក់ មិនត្រឹមតែធ្វើការពន្យល់អំពីការងាររបស់ពួកគេប៉ុណ្ណោះទេ ថែមទាំងអាចទាក់ទាញ អតិថិជនផងទៀត។ សកម្មភាពនេះក៏អាចជាការលើកទឹកចិត្តមួយដើម្បីជួយសាលានៅក្នុងសកម្មភាពបំណិនជីវិតនេះផងដែរ។ នេះអាចមានន័យថាជាងកាត់សក់អាចត្រូវបានអញ្ជើញឱ្យមកចូលរួមក្នុងការធ្វើបទបង្ហាញដ៏តូចមួយ ដែលគាត់អាចធ្វើការបង្ហាញបាន ឬក៏ផ្តល់ជាការកាត់សក់ជូនសិស្ស។

● ប្រសិនបើមិនអាចធ្វើបានដោយសារតែផ្លូវឆ្ងាយក្នុងការទៅទស្សនាហាងកាត់សក់នោះ អ្នកក៏អាចអញ្ជើញជាងកាត់សក់ម្នាក់ឱ្យមកសាលា ហើយប្រាប់ពីការងាររបស់គាត់ក៏បាន។

របៀបធ្វើឱ្យកន្ត្រៃតុងជីមុត៖ ដោះខ្ចៅនៅផ្នែកខាងលើរបស់កន្ត្រៃ ដើម្បីដោះយកបន្ទះធ្មេញរបស់វាមកសំលៀង ។ បន្ទាប់មកដាក់កាកស៊ីលាយជាមួយប្រេង នៅលើកញ្ចក់សំលៀង ដែលក្រាសនិងសំប៉ែត។

ក្រោយមកយើងជុះវាទៅមកៗជាច្រើនដង ហើយបន្ទាប់មកទៀតស្ទាប វាមើលថា តើវាមុតឬនៅ។ ប្រសិនបើវាមុតយើងឈប់ ហើយយកផ្នែកផ្សេងមួយទៀតមកសំលៀងរហូតដល់វាមុត ។ នៅពេលសំលៀងរួចរាល់ហើយ យើងដាក់វាចូលទៅក្នុងកន្ត្រៃវិញ។

*ចំណាំ៖ យើងក៏អាចធ្វើឱ្យកន្ត្រៃមុតល្អបាន ប្រសិនបើយើងមានម៉ូទ័រ ដើម្បីភ្ជាប់ទៅនឹងធ្មេញកន្ត្រៃ ដែលអាចសំលៀងបានលឿនជាងការសំលៀងដោយដៃ។*



### *ជាងកាត់សក់*

អ្នកធ្វើជារវល់កាត់សក់ឱ្យនរណាម្នាក់។ បន្ទាប់មក ក៏មានភ្ញៀវម្នាក់ចូលមកដល់។ គាត់ចង់ឱ្យអ្នកកាត់សក់ឱ្យគាត់មុន។ តើអ្នកត្រូវធ្វើដូចម្តេច?



### *អតិថិជន*

អ្នកចូលទៅក្នុងហាងកាត់សក់មួយ ហើយឃើញថាជាងកំពុងរវល់។ អ្នកមានការប្រញាប់ ដូច្នេះហើយអ្នកចង់ឱ្យគាត់កាត់សក់ឱ្យមុន។ ពេលនោះអ្នកបានព្យាយាម ធ្វើអ្វីគ្រប់បែបយ៉ាង។ ដំបូងអ្នកចង់ឱ្យគាត់នូវតម្លៃទ្វេ ហើយអ្នកព្យាយាមប្រាប់ជាងកាត់សក់ថា អ្នកពិតជាចង់កាត់សក់ឱ្យបានលឿន ដោយសារតែអ្នកចង់ឱ្យមើលទៅល្អនៅយប់នេះ ពីព្រោះអ្នកបានណាត់ជាមួយ នឹងមនុស្ស ប្រុស/ស្រីម្នាក់។

### *ជាងកាត់សក់*



អ្នកទើបតែកាត់សក់ឱ្យគេរួច ប៉ុន្តែភ្ញៀវមិនពេញចិត្ត។ គេនិយាយថា ពួកគេចង់ បានសក់រួញ មិនមែនត្រង់ទេ។ អ្នកក៏បានដឹងផងដែរថា គេជាអ្នកខុស ដោយសារតែគេនិយាយថា ឱ្យកាត់សក់ត្រង់។ តើអ្នកត្រូវធ្វើដូចម្តេច?

### *អតិថិជន*

ជាងកាត់សក់បានកាត់សក់របស់អ្នក។ ដោយសារតែអ្នកមិនចង់ចំណាយលុយច្រើន អ្នកបែរជានិយាយថាអ្នកមិនពេញចិត្តនឹងម៉ូតសក់នោះ។ អ្នកចង់បានសក់រួញ មិនមែនត្រង់ដូចឥឡូវនោះទេ! អ្នកធ្វើការត្អូញត្អែរ។ នៅពេលដែលអ្នកគិតថា ជាងកាត់សក់បានធ្វើការងារដ៏ល្អ ដោយបានធ្វើការពន្យល់អ្នកអំពីបញ្ហានោះ ហើយអ្នកក៏បានសារភាពថា អ្នកខុស ហើយបានចាកចេញពីហាង។

### *ជាងកាត់សក់*

ចៃដន្យអ្នកបានធ្វើឱ្យមុតក្មេងម្នាក់ ដែលនៅមិនស្ងៀមនៅលើកៅអី។ គាត់/នាងបានយំ ហើយម្តាយរបស់គាត់/នាងក៏បានរត់មករកអ្នក។ តើអ្នកត្រូវធ្វើដូចម្តេច?

### *អតិថិជន*

អ្នកធ្វើជាលេងថា អ្នកជាម្តាយ/ឪពុករបស់ក្មេងនោះ ហើយជាងកាត់សក់បានធ្វើឱ្យមុតកូនរបស់អ្នកដោយចៃដន្យ។ អ្នកចង់ដឹងថា ហេតុអ្វីបានជាមានរឿងនោះកើតឡើង ហើយអ្នកក៏ខឹងនឹងជាងកាត់សក់នោះ។ សួរ រកហេតុផល និងពីរបៀបដែលជាងកាត់សក់គិតថា មិនគួរធ្វើដូច្នេះនៅថ្ងៃខាងមុខទៀត។



### *ជាងកាត់សក់*

មានបុរសម្នាក់ដែលមានលុយត្រឹមតែ២០០០ រៀល ហើយចង់ឱ្យអ្នកជួយកាត់សក់ឱ្យគាត់។ ដោយសារតែគាត់មានលុយមិនគ្រប់ ដូច្នេះគាត់ចង់ឱ្យអ្នកកាត់សក់គាត់តែផ្នែកខាងលើ ហើយទុកផ្នែកខាងក្រោយ។ តើអ្នក ត្រូវធ្វើដូចម្តេច ដើម្បីជួយបុរសម្នាក់នោះ?



### *អតិថិជន*

អ្នកនិយាយថា អ្នកមានលុយត្រឹមតែ២០០០ រៀល ប៉ុន្តែការពិតអ្នកមានលុយច្រើនជាងនេះ ។ អ្នកចង់ឱ្យគេកាត់សក់ឱ្យដោយអស់តម្លៃតិច ដោយបាននិយាយថា អ្នកគ្រាន់តែចង់ឱ្យគេកាត់សក់ផ្នែកខាងលើរបស់អ្នក។ នៅពេលដែលជាងកាត់សក់ពន្យល់ថា ការកាត់បែបនោះ គឺមើលទៅមិនល្អនោះទេ ហើយអ្នកសួរថា "ហេតុអ្វីបានជាមិនល្អមើល ?" នៅពេលដែលជាងកាត់សក់ធ្វើការពន្យល់ បានល្អ អ្នកក៏បានសារភាពថា អ្នកមានលុយច្រើនជាងនេះទៅទៀត។

# មេរៀនទី ៣: ការទស្សនាហាងកាត់សក់

🕑 រយៈពេលបង្រៀន: ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- មានកង់មួយសម្រាប់ជាងកាត់សក់ ប្រសិនបើគាត់ត្រូវដើរចំណាយពេល១៥នាទី
- សៀវភៅសម្រាប់កត់ត្រា សម្រាប់សិស្សទាំងអស់គ្នា ដែលត្រូវយកទៅដើម្បីកត់ត្រានូវចម្លើយមួយចំនួន។

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- ស្រាវជ្រាវដោយផ្អែកទៅលើសំណួរ និងការកត់សម្គាល់ដែលបានរៀបចំរបស់ពួកគេ
- ឆ្លុះបញ្ចាំងពីចំណេះដឹងរបស់ពួកគេ អំពីជាងកាត់សក់ មកលើការពិត និងឃើញនូវភាពខុសគ្នា និងដូចគ្នា។

**សេចក្ដីផ្ដើម** ៖ ចាត់ចែងត្រៀមខ្លួនជាស្រេច 🕑 ១០ នាទី

👄 ថ្ងៃនេះយើងនឹងទៅជួបជាងកាត់សក់។ គ្រប់ៗគ្នាក៏បានរៀបចំយ៉ាងហោចណាស់ នូវសំណួរចំនួន៥ និងការអង្កេតមើលចំនួន២។

◈ តើនរណាមានសំណួរល្អ ដែលអ្នកអាចធ្វើការចែករំលែកបាន?

👄 សួរសិស្សពីរឬបីនាក់ថា តើអ្វីខ្លះដែលជាការសង្កេតរបស់ពួកគេ។ តើព័ត៌មានអ្វីខ្លះដែលពួកគេចង់បាន ហើយតើពួកគេត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលបាននូវព័ត៌មានទាំងនោះ?

ដោយសារតែយើងទាំងអស់គ្នានឹងទៅធ្វើទស្សនកិច្ចនៅខាងក្រៅសាលា ដូច្នេះយើងចាំបាច់ ត្រូវបង្កើតនូវវិន័យជាមូលដ្ឋានមួយចំនួន ដើម្បីជួយឱ្យគ្នាយើងមានសុវត្ថិភាព។

◈ តើមាននរណាអាចប្រាប់ខ្ញុំ អំពីច្បាប់ចរាចរតាមផ្លូវមាន?

👄 នៅពេលដែលកំពុងបើកបរ ឬធ្វើដំណើរថ្មើរជើងនៅតាមផ្លូវ អ្នកមិនអាចដើរទន្ទឹមគ្នា ដែលមានចំនួនលើសពី ២ នាក់នោះទេ។ ប្រសិនបើអ្នកបើកបរ ឬដើរនៅខាងស្ដាំ ឬខាងឆ្វេង អ្នកត្រូវក្រឡេក មើលខាងលើស្មារបស់អ្នក ដើម្បីពិនិត្យមើលថា តើមានការធ្វើចរាចរកំពុងតែមាននៅលើផ្លូវ អ្នកដែរឬទេ។ នៅពេលដែលអ្នកបត់ឆ្វេង ឬស្ដាំ ចូរធ្វើសញ្ញា

ដោយប្រើដៃរបស់អ្នក ដូច្នេះអ្នកដែលធ្វើដំណើរនៅខាងក្រោយ និងខាងមុខអ្នកអាចដឹងថា កន្លែងណាដែលអ្នកចង់បត់ ហើយពួកគេក៏ងាយស្រួលស្មានទុកផងដែរ។

តើយើងទាំងអស់គ្នាបានត្រៀមខ្លួនរួចរាល់សម្រាប់ចេញដំណើរហើយមែនទេ?
គ្រប់គ្នាជិះកង់របស់ពួកគេ ឬក៏ជិះជាជួរៗ ហើយគ្រូស្ថិតនៅខាងមុខដើម្បីនាំផ្លូវ។

**សកម្មភាពសំខាន់។** ៧០ នាទី

ជួបជុំសិស្សទាំងអស់នៅខាងមុខហាងកាត់សក់ ហើយធ្វើការសម្រេចចិត្តថា តើសិស្សប៉ុន្មាននាក់ដែលអាចចូលទៅខាងក្នុងហាងបាន។ ប្រាប់សិស្សដទៃៗទៀតថា ពួកគេអាចធ្វើការសង្កេត របស់ពួកគេបាននៅចន្លោះពេលនីមួយៗ។

យើងនឹងក្រឡេកទៅមើលផ្នែកខាងក្នុងហាងជាមុនសិន បន្ទាប់មកទៀត ជាងកាត់សក់នឹងផ្តល់ឱ្យយើងនូវព័ត៌មានមួយចំនួនទៀត។ បន្ទាប់មកយើងក៏អាចសាកសួរ គាត់នូវសំណួរមួយចំនួន ដែលយើងចង់ឱ្យគាត់ឆ្លើយសម្រាប់ការស្រាវជ្រាវរបស់យើង។

ព្យាយាមផ្តល់ឱ្យសិស្សដទៃៗទៀត តាមដែលអាចធ្វើទៅបាននូវឱកាសសម្រាប់ធ្វើការសួរ សំណួរ។ក្រើនរំឭកពួកគេថា វាសំខាន់ណាស់ដែលត្រូវស្តាប់គ្នា ដោយសារតែយើង មិនចង់ឱ្យ មានការសួរសំណួរដដែលៗនោះទេ។

នៅចុងបញ្ចប់ ចូរធ្វើការស្នើសុំសិស្សស្ម័គ្រចិត្តមួយរូប ឱ្យជាងកាត់សក់របស់គេ (ងាយស្រួល និងលឿន!)។ នេះគឺអាច ត្រូវបានធ្វើដោយជាងកាត់សក់ នៅខណៈពេលដែលសិស្សដទៃទៀតកំពុងធ្វើការសង្កេតមើល ហើយពិនិត្យមើលអ្វីដែលគាត់ធ្វើទាក់ទងទៅនឹងអនាម័យ ភាពរួសរាយរាក់ទាក់ចំពោះអតិថិជន និងពីរបៀបដែលគាត់ប្រើប្រាស់សម្ភារៈរបស់គាត់។

អរគុណអ្នកខ្លាំងណាស់ ដែលបានផ្តល់នូវឱកាសឱ្យពួកយើងមកធ្វើទស្សនកិច្ចសិក្សានៅហាងរបស់អ្នក។ យើងត្រូវនាំគ្នាត្រឡប់ទៅកាន់សាលាវិញ ក៏ប៉ុន្តែយើងចង់អញ្ជើញអ្នក ឱ្យទៅធ្វើបទ បង្ហាញចុងក្រោយរបស់អ្នកមួយស្តីអំពីការកាត់សក់។

ប្រមូលផ្តុំសិស្សទាំងអស់គ្នា ហើយវិលត្រឡប់មកកាន់សាលាវិញ។

**បញ្ចប់មេរៀន** ១០ នាទី

ប្រសិនបើមានពេលនៅសល់ អ្នកអាចលេងល្បែងធម្មតាមួយ។ ខ្ញុំទៅជួបជាងកាត់សក់ ហើយ ខ្ញុំបានយកទៅជាមួយនូវ...

សិស្សទាំងអស់ត្រូវនិយាយបំពេញល្បះ បន្ទាប់ពីសិស្សម្នាក់បន្ថែមនូវពាក្យមួយ ឧទាហរណ៍៖ កន្ត្រៃ ដូច្នេះសិស្សបន្ទាប់ទៀតត្រូវនិយាយថា ខ្ញុំទៅជួបជាងកាត់សក់ ហើយបានយកទៅជាមួយនូវ កន្ត្រៃ និងក្រាសមួយ។ សិស្សទី៣ ត្រូវបន្តទៀតដោយនិយាយថា ខ្ញុំទៅជួបនឹងជាង កាត់សក់ ហើយបានយកទៅជាមួយនូវកន្ត្រៃ ក្រាស និងសាប៊ូ...និងមានតទៅទៀតរហូតដល់ក្លាយទៅជាឃ្លាដ៏វែងមួយដែលមិនអាចចងចាំបាន។

ចំពោះកិច្ចការផ្ទះរបស់អ្នកទាំងអស់គ្នាគឺៈ សរសេរនូវរបាយការណ៍មួយ ពីទស្សនកិច្ចសិក្សានៅហាងកាត់សក់។ ការធ្វើរបាយការណ៍នេះត្រូវតែរួមបញ្ចូល៣ផ្នែកសំខាន់ៗ។

១. ការរៀបចំ (របៀបដែលខ្ញុំបានរៀបចំនៅក្នុងថ្នាក់)
២. សកម្មភាព(អ្វីខ្លះដែលយើងបានធ្វើនៅអំឡុងពេលធ្វើដំណើរ)
៣. បានសិក្សា (តើអ្វីខ្លះដែលជាចម្លើយចំពោះសំណួរ និងការសង្កេតរបស់ខ្ញុំ?)

## សេចក្ដីណែនាំគ្រូ

ជាការសំខាន់ណាស់ដែលត្រូវរៀបចំទស្សនកិច្ចនេះឱ្យបានល្អ។ ដោយអាស្រ័យទៅលើជំនាញនៃការបង្រៀនរបស់ជាងកាត់សក់ គ្រូក៏អាចជួយជាងកាត់សក់បន្តិចបន្តួចដោយធ្វើការពន្យល់ពីអ្វីដែលគាត់អាចប្រាប់បាន។

នេះអាចរួមមានការប្រាប់អំពី ៖

- ឈ្មោះ អាយុរបស់គាត់ និងប្រាប់ពីអាយុដែលគាត់បានក្លាយទៅជាជាងកាត់សក់
- ការអប់រំរបស់គាត់ ឬពីវិធីដែលគាត់ក្លាយទៅជាជាងកាត់សក់
- ទម្លាប់ធម្មតានៅអំឡុងពេលមួយថ្ងៃៗរបស់គាត់
- តើឧបករណ៍ណាមួយដែលគាត់ប្រើប្រាស់ជារឿយៗ ហើយតើគាត់អាចបង្ហាញឧបករណ៍នេះទៅកាន់សិស្សទាំងអស់គ្នាបានដែរទេ?
- តើអ្វីដែលគាត់ចូលចិត្តធ្វើជាងគេបំផុតនៅក្នុងការងាររបស់គាត់?
- សម្ភារៈដែលមាននៅក្នុងហាងរបស់គាត់

ជាការសំខាន់ផងដែរ ដែលជាងកាត់សក់គួរត្រៀមដើម្បីឆ្លើយនឹង សំណួរជាច្រើនដែលសិស្សសួរ។ វាអាចដោយសារតែហាងកាត់សក់តូចបន្តិចសម្រាប់សិស្សទាំងអស់គ្នា ដូច្នេះអ្នកអាចឱ្យសិស្សទាំងអស់បង្កើតជាក្រុមតូចៗ។

ចុងបញ្ចប់ធ្វើការរៀបចំជាងកាត់សក់នូវប្រធានបទចំនួនប្រហែលជា ៣ ដែលត្រូវបានធ្វើការ ពិភាក្សានៅក្នុងក្រុមដូចជាអនាម័យ ការរួសរាយរាក់ទាក់ចំពោះភ្ញៀវ និងការប្រើប្រាស់ ឧបករណ៍ទាំងនោះ។ សិស្សត្រូវយកចិត្តទុកដាក់ចំពោះចំណុចនោះ ហើយចំណែកឯជាងកាត់សក់ក៏ត្រូវធ្វើការរៀបចំឱ្យបានល្អផងដែរ។

ដោយយោងទៅតាមការអប់រំ ដែលចាំបាច់ក្នុងការក្លាយទៅជាជាងកាត់សក់មួយរូប ដូច្នេះ នេះអាចជាព័ត៌មានដែលមានសារប្រយោជន៍សម្រាប់សិស្សទាំងអស់គ្នាដែលត្រូវដឹង។ មាន មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈជាច្រើន ដោយអាស្រ័យទៅលើបណ្ដាខេត្តមួយចំនួនដែល បានផ្ដល់ជាជំនួយក្នុងការហ្វឹកហាត់។ មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈពីអង្គការមិត្តសម្លាញ់ នៅក្នុងខេត្តសៀមរាប គឺជាឧទាហរណ៍គំរូចំពោះការហ្វឹកហាត់ទាំងនោះ។

ចំណែកឯនៅក្នុងខេត្តកំពង់ចាមវិញ គឺមានសមាគមអភិវឌ្ឍន៍សង្គមសាសនាព្រះពុទ្ធ ដែល អាចផ្ដល់ជាបណ្ដាញមួយចំពោះការអប់រំក្រៅផ្លូវការ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

ការរៀបចំទាំងនេះគឺមានលក្ខណៈងាយស្រួល និងដឹងពីរបៀបក្នុងការស្វែងរកទំនាក់ទំនងជាមួយនឹងមន្ទីរអប់រំខេត្ត ឬក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដើម្បីធ្វើការស្វែងរកនូវព័ត៌មានបន្ថែម អំពីចំណុចនេះ។

# មេរៀនទី ៤: ម៉ូតសក់

🕑 រយៈពេលបង្រៀន: ២ ម៉ោង

☑ ការត្រៀមលក្ខណៈ:

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ ?
- សរសេរសំណួរសិក្សាលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)

🕮 សម្ភារឧបទេស ធនធានដែលត្រូវការ

- ក្រដាសធំពីរបីសន្លឹក ដើម្បីទុកបិទរបាយការណ៍
- ផ្ទាំងរូបភាពម៉ូតសក់ប្លែកៗគ្នា។ កុំទាន់ដាក់វានៅលើជញ្ជាំង
- កាត់ប័ណ្ណតូចៗចំនួន៦០សន្លឹក ដែលមានប្រវែងបណ្ដោយប្រហែលជា ៥សម ទទឹង ៣សម ក្រុមទាំងអស់នឹងទទួលបានប័ណ្ណចំនួន ១០សន្លឹក/ក្រុម។

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- បង្ហាញពីលទ្ធផលនៃទស្សនកិច្ចសិក្សានៅហាងកាត់សក់
- កំត់ពីម៉ូតសក់ខុសៗគ្នា និងលក្ខណៈនៃម៉ូតសក់ទាំងនេះ ដែលបង្ហាញឱ្យដឹងពីចរិតលក្ខណៈរបស់មនុស្ស។
- ប្រាប់ពីស្ថានការណ៍ ដែលកំពុងតែកើតឡើងនៅក្នុងជីវិតរបស់ពួកគេផ្ទាល់ ហើយបង្កើតជាសំណួរថា តើពួកគេជាអ្វី និងពួកគេដូចអ្វី។ នេះក៏ជាផ្នែកមួយនៃបុគ្គលិកលក្ខណៈរបស់ពួកគេផងដែរ។

**សេចក្ដីផ្ដើម** : ការក្រឡេកមើលទៅក្រោយវិញ 🕑 ២០ នាទី

👄 កាលពីសប្ដាហ៍មុន យើងទាំងអស់គ្នាបានទៅហាងកាត់សក់មួយ។ អ្នកទាំងអស់គ្នាក៏បានសរសេររបាយការណ៍មួយស្ដីអំពីទស្សនកិច្ចសិក្សារបស់អ្នកផងដែរ។ យើងមិនអាចអានវាឱ្យឮៗបានទេ ក៏ប៉ុន្តែយើងនឹងធ្វើការជ្រើសរើសយកចំណុចពីរឬបីមកនិយាយ។ ចំណែកឯចំណុចផ្សេងទៀត ដែលនៅសល់ នឹងត្រូវដាក់ព្យួរនៅលើជញ្ជាំង ហើយនឹងអានវាក្នុងអំឡុងពេលសិក្សានៅសប្ដាហ៍ក្រោយៗទៀត។

? តើនរណាចង់អានរបាយការណ៍ផ្ទាល់ខ្លួនស្ដីអំពីទស្សនកិច្ចសិក្សានៅហាងកាត់សក់ ?

✋ ជ្រើសរើសយកឧទាហរណ៍ល្អៗពីរឬបី ហើយធ្វើការលើកសរសើរសិស្សចំពោះការខិតខំប្រឹង ប្រែងរបស់ពួកគេ។ អ្នកមិនចាំបាច់បង្ហាញថា តើរបាយការណ៍នេះមានរយៈពេលប៉ុន្មានទេ ដូច្នេះរបាយការណ៍ទាំងអស់ គឺនិយាយអំពីការឆ្លើយចំពោះសំណួររបស់ពួកគេ។ ប្រសិនបើ ពួកគេធ្វើបាន ល្អគ្រប់គ្រាន់ ដូច្នេះពួកគេនឹងទទួលបានការសរសើរចំពោះកិច្ចការនេះ។



បន្ទាប់មក ឱ្យសិស្សទាំងអស់យករបាយការណ៍របស់ពួកគេ បិទឱ្យបានល្អ នៅលើក្រដាសធំមួយ។

ថ្ងៃនេះ យើងនឹងធ្វើការពិនិត្យមើលសក់ផ្ទាល់ខ្លួនរបស់ យើង ក៏ប៉ុន្តែជាដំបូងយើងត្រូវស្គាល់ពីសក់របស់យើងជាមុន សិន។ ខ្ញុំត្រូវការអ្នកស្ម័គ្រចិត្តមួយរូប ដែលនឹងត្រូវបានគេបិទ ភ្នែក។ យើងក៏ត្រូវការសិស្សចំនួន ៦នាក់ ទៀតផងដែរដើម្បី ឈរនៅខាងមុខ សិស្សរួមថ្នាក់ទាំងអស់។ ចំពោះសិស្សដែល ត្រូវបានគេបិទភ្នែកដំបូង គេអាចមើលឃើញថានរណា ដែលកំពុងអង្គុយនៅទីនោះ បន្ទាប់មកនឹងត្រូវបាន គេយកទៅដាក់នៅខាងក្រោយកៅអីមួយ ដោយនៅបិទភ្នែក ដដែល។ សិស្សម្នាក់ក្នុងចំណោមសិស្សទាំងអស់នឹងអង្គុយនៅលើកៅអី ហើយ "**ជាងកាត់សក់**" ត្រូវតែទាយ ថា តើនោះ គឺជានរណា។

អ្នកត្រូវតែធ្វើការទស្សន៍ទាយដោយប្រើចុងម្រាមដៃរបស់អ្នកដើម្បីស្ទាបសក់ និងមុខរបស់សិស្សដែលកំពុងអង្គុយ នៅលើកៅអី។ *ចូរប្រើតែចុងម្រាមដៃរបស់អ្នក បើមិនដូច្នោះទេអ្នកនឹងអាចធ្វើឱ្យអ្នកដទៃមានការឈឺចាប់។*

បន្ទាប់ពីលេងល្បែងនេះពីរបីដងរួចមក ចូរធ្វើការសន្និដ្ឋានថា វាគឺអាចទៅរួច ដើម្បី ស្គាល់នរណាម្នាក់ តាមរយៈសក់ និងមុខរបស់ពួកគេ បើទោះបីជាមើលមិនឃើញពួកគេ ក៏ដោយ។

## កម្មភាពសំខាន់។

៤០ នាទី

ជួនកាល សូម្បីតែម៉ូតសក់ក៏អាចប្រាប់យើងនូវអ្វីៗមួយចំនួនពីបុគ្គលម្នាក់ផងដែរ។ ជាពិសេសនៅអំឡុងប៉ុន្មានឆ្នាំ មុន ប្រជាជនកម្ពុជាមិនមានការប្រកាន់ឡើយ ចំពោះការមើលឃើញ លក្ខណៈខុសៗគ្នា។ ជួនកាលពួកគេក៏ចូលចិត្តធ្វើ ឱ្យខ្លួន មើលទៅមានលក្ខណៈខុសប្លែកផងដែរ។ ពួកគេចូលចិត្តធ្វើឱ្យមានភាពលេចធ្លោហើយទទួលបាននូវការចាប់អារម្មណ៍។ វាគឺពិតជាល្អដែលមើលទៅឃើញប្លែក ក៏ដូចជាមើលទៅឃើញដូចនឹងអ្នកដទៃ។ មនុស្សទាំងអស់គ្នាចាំបាច់ត្រូវ តែអាចសម្របខ្លួន ទៅតាមស្ថានការណ៍ខុសៗគ្នា។ នោះគឺមានន័យថា ប្រសិនបើអ្នកចង់ឱ្យម៉ូតសក់របស់អ្នកមើលទៅ ខុសប្លែកពីអ្នកដទៃនោះ មនុស្សដែលនៅជុំវិញអ្នកនឹងធ្វើការកត់សម្គាល់ ក៏ដូចជាផ្តល់នូវមតិរិះគន់មួយចំនួន។ បន្ទាប់ ពីមួយរយៈក្រោយមក ពួកគេទាំងអស់នោះស៊ាំទៅនឹងស្ថានការណ៍បែបនោះ ហើយវាក៏ក្លាយទៅជាធម្មតា លើកលែងតែ នៅពេល ដែលអ្នកជួបនឹងមនុស្សថ្មីៗទៀត។ ការមានគំនិតខុសប្លែកគ្នា ឬការ មើលទៅឃើញ ខុសៗគ្នា ក៏តម្រូវឱ្យអ្នក ចាំបាច់សម្របខ្លួនទៅនឹងអ្វី ដែលមនុស្សជាច្រើនគិតថាអាចទទួលយកបាន។ អ្នកក៏ត្រូវតែ អាចធ្វើដូច្នោះបានផងដែរ។

ឧទាហរណ៍: ចូលចិត្តសក់ដែលមានពណ៌ខ្មៅ លាយជាមួយពណ៌លឿងខ្ចី ហើយចំពោះ មិត្តភក្តិរបស់អ្នកវិញ គឺគេ មិនថាអ្វីនោះទេ។ នៅពេលដែលអ្នកទៅលេងលោកតារបស់អ្នក ពេលនោះគាត់ក៏បានសួរអ្នកថា តើអ្នកឈឺមែនទេ? គាត់ពិតជាមិនចូលចិត្តសក់បែបនោះទេ ហើយគាត់ក៏គិតផងដែរថា អ្នកប្រហែលជាឆ្កួតហើយ។

តើអ្នកគួរតែធ្វើដូចម្តេច?

អ្នកត្រូវសម្របខ្លួនតាមស្ថានការណ៍នោះ ដោយពេលទៅជួបនឹងលោកតា អ្នកអាចធ្វើសក់ឱ្យមានពណ៌ខ្មៅឡើងវិញ ហើយត្រូវមានម៉ូតឱ្យកាន់តែមើលទៅមានលក្ខណៈបែបប្រពៃណី។

ដូច្នេះយើងទាំងអស់គ្នាត្រូវដឹងពីពេលវេលា និងរបៀបប្រើប្រាស់ម៉ូតសក់ប្លែកៗ។ ចូរនាំគ្នាក្រឡេកមើលម៉ូតសក់មួយចំនួន។

ជ្រើសរើសយកប័ណ្ណមួយសន្លឹកចេញពីក្នុងឯកសារ៤.១ សម្រាប់សិស្ស ហើយព្យួរវានៅលើក្ដារខៀន។ ឱ្យសិស្សធ្វើការបញ្ចេញមតិចំពោះរូបភាពនោះរយៈពេលមួយសន្ទុះ។

តើម៉ូតសក់មួយណា ដែលនាំឱ្យមានការរិះគន់?

ចូរធ្វើការពិភាក្សាគ្នាបន្តិចអំពីម៉ូតសក់។ តើម៉ូតសក់បែបណាដែលសិស្សចូលចិត្ត ហើយមួយណាដែលពួកគេមិនចូលចិត្ត។

ជាការពិតណាស់ ចំពោះសក់ គឺមានច្រើនម៉ូត។ ម៉ូតសក់មួយចំនួនប្រាប់អ្នកអំពីលក្ខណៈរបស់មនុស្សដែលកំពុងតែប្រើម៉ូតសក់នោះ។ ចំណែកឯម៉ូតផ្សេងៗទៀត គឺគ្រាន់តែត្រូវបានជ្រើសរើសយកមកប្រើប្រាស់ ដោយសារតែមនុស្សជាច្រើនចូលចិត្តម៉ូតសក់ទាំងនោះ ពីព្រោះវា សមស្របទៅនឹងមុខរបស់ពួកគេ។ ប៉ុន្តែម៉ូតសក់មួយចំនួនធ្វើឱ្យយើងមិនពេញចិត្តផងដែរ។ នោះហើយ គឺជាអ្វីដែលយើងមើលឃើញ។ ដូច្នេះ អ្វីមួយចំនួនក៏បានកើតមានឡើងជាមួយនឹងម៉ូតសក់ទាំងនោះផងដែរ។ ខ្ញុំនឹងផ្តល់ឱ្យក្រុមនីមួយៗ នូវប័ណ្ណតូចៗចំនួន ១០សន្លឹក។ ខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នាគិតពីពាក្យ ២ម៉ាត់ ដែលកើតចេញពីម៉ូតសក់ខុសៗគ្នាជាច្រើន។ នៅពេលដែលអ្នកទាំងអស់គ្នា បានគិតពីពាក្យទាំងនោះរួចរាល់ហើយ ចូរបិទវានៅក្បែររូបភាពដែលមាននៅលើក្ដារខៀន។ វាមិនមានអ្វីខុស ឬត្រូវនោះទេ ដោយសារតែនេះ គឺជាការនិយាយអំពី អារម្មណ៍ និងការគិតតែប៉ុណ្ណោះ។

ចែកឱ្យសិស្សទាំងអស់គ្នានូវប័ណ្ណតូចៗចំនួន១០សន្លឹក។ ឱ្យសិស្សធ្វើការពិភាក្សាគ្នា រយៈពេល ១០នាទី ហើយប្រាប់ពួកគេឱ្យព្យួរប័ណ្ណទាំងនោះនៅលើក្ដារខៀន។

ខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នាឡើងមកខាងមុខ ហើយខ្ញុំនឹងផ្តល់ឱ្យក្រុមនីមួយៗនូវរូបភាពមួយសន្លឹក ព្រមទាំងប័ណ្ណតូចៗទាំងអស់ដែលនៅជាប់នឹងវា ។ អ្នកទាំងអស់គ្នាអាចធ្វើការសម្រេចចិត្តក្នុងក្រុមរបស់អ្នក ពីរបៀបដែលអ្នកនឹងត្រូវរៀបប័ណ្ណនោះទៅតាមផ្នែក ដែលខុសគ្នា និងដូចគ្នា ។

ឱ្យក្រុមទាំងអស់ធ្វើការសម្រេចចិត្តពីភាពដូចគ្នា និងភាពខុសគ្នា បន្ទាប់មកស្នើឱ្យក្រុមទាំងអស់ធ្វើការកត់ត្រានូវផ្នែកដែលខុសគ្នានោះ។

**បញ្ចប់មេរៀនៈ** ម៉ូតសក់របស់ខ្ញុំ ⌚ ៣០ នាទី

ចំពោះកិច្ចការចុងក្រោយរបស់យើង គឺនិយាយអំពីម៉ូតសក់របស់ខ្លួនផ្ទាល់។ គ្រប់ៗគ្នាអាចបង្កើតជាផែនទីគំនិតផ្ទាល់ខ្លួនមួយ (ដូចដែលយើងបានធ្វើនៅក្នុងមេរៀនទី១) ទាក់ទងទៅនឹង ប្រធានបទ *"ម៉ូតសក់របស់ខ្ញុំ"*។

តើអ្វីទៅជាម៉ូតសក់របស់ខ្ញុំ? តើរបស់មួយណា ដែលត្រូវនឹងម៉ូតសក់របស់អ្នក? អ្នកទាំងអស់គ្នាអាចបង្ហាញឈ្មោះអ្វីៗជាច្រើន។ ឧទាហរណ៍៖

- តើអ្នកចូលចិត្តអ្នកដទៃនូវចំណុចអ្វីខ្លះ?
- តើម្ហូប ភេសជ្ជៈ ឬសកម្មភាពអ្វីខ្លះដែលជាចំណង់ចំណូលចិត្តរបស់អ្នក?
- តើអ្នកមានអារម្មណ៍ដូចម្តេច នៅពេលស្ថិតនៅក្នុងពេលវេលាខុសគ្នានៃថ្ងៃនីមួយៗ?
- តើអ្នកសប្បាយរីករាយ ក្រៀមក្រំ ខឹង ធម្មតា ធុញថប់ដោយសារអ្វីខ្លះ?

ចូរគិតតែម្នាក់ឯងយ៉ាងហោចណាស់ឱ្យបានរបស់ ចំនួន១៥ ដែលទាក់ទងទៅនឹងម៉ូតសក់របស់អ្នក។ អ្នកមានរយៈពេល ៥នាទី សម្រាប់ការគិតនេះ។

ឱ្យសិស្សទាំងអស់គ្នាបំពេញនូវផែនទីគំនិត រហូតដល់អ្នកមើលឃើញថា គ្រប់ៗគ្នាបានសរសេរចូលនូវអ្វីៗមួយចំនួនហើយ។

ដូច្នេះ តើអ្នកអាចបង្ហាញម៉ូតសក់របស់អ្នកដោយវិធីណា ហើយអ្វីដែលមានសារៈសំខាន់ចំពោះអ្នក តាមរយៈម៉ូតសកនេះ?

គ្រប់ៗគ្នាអាចគូរគំនូរមួយ ដែលជារូបម៉ូតសក់សមនឹងខ្លួនឯង ។ អ្នកនឹងគូររូបនេះ ដោយប្រើខ្មៅដៃពណ៌។ គំនូរនេះគឺជាកិច្ចការផ្ទះរបស់អ្នក ដូច្នេះអ្នកទាំងអស់គ្នាអាចយកវាទៅគូរនៅផ្ទះក៏បានដែរ។

នៅសប្តាហ៍ក្រោយ យើងនឹងសិក្សាពីម៉ូតសក់របស់អ្នក ហើយពិនិត្យមើលពីរបៀប ដែលអ្នកធ្វើឱ្យមានការទាក់ទងគ្នារវាងម៉ូត និងសក់របស់អ្នក។ ចូរកុំភ្លេចថា នេះគឺជាម៉ូត និង គំនិតផ្ទាល់ខ្លួន ដែលមិនអាចធ្វើឱ្យខុស ហើយក៏មិនអាចត្រូវបានធ្វើការវិនិច្ឆ័យ ដោយអ្នកដទៃ ផងដែរ។ *មើលសេចក្តីណែនាំគ្រូ។*

អ្នកទាំងអស់គ្នាមិនចាំបាច់គូររូបមុខមាត់ពិតរបស់អ្នកនោះទេ គឺគ្រាន់តែគូរគ្រោងរបស់វាទៅ គ្រប់គ្រាន់ហើយ។

ឱ្យសិស្សទាំងអស់គ្នាធ្វើការអនុវត្តដោយប្រើខ្មៅដៃ មុនពេលដែលពួកគេចាប់ផ្តើមគូរគំនូរចុងក្រោយ។ ប្រសិនបើអាច ចូរធ្វើការបង្ហាញពួកគេនូវឧទាហរណ៍ឱ្យបានច្រើន។ ចំពោះការ បង្ហាញនេះផងដែរ គឺផ្ទាំងរូបភាពម៉ូតសក់អាចនឹងត្រូវបានប្រើប្រាស់។ ការពិត ចូរប្រាប់ពួកគេ ថា នេះគ្រាន់តែជាឧទាហរណ៍ទេ ហើយចំពោះការគូររបស់ពួកគេវិញ គឺត្រូវធ្វើការរចនាដោយខ្លួនរបស់ពួកគេផ្ទាល់។ ចំពោះការគូរនេះ អាចត្រូវបានផ្តល់ឱ្យទៅសិស្សធ្វើជាកិច្ចការផ្ទះ សម្រាប់សប្តាហ៍ក្រោយ។

# សេចក្ដីណែនាំគ្រូ

ល្បែងបិទភ្នែកអាចត្រូវបានលេងជាក្រុមចំនួន៦ក្រុមដូចៗគ្នា ប្រសិនបើគ្រូគិតថាការធ្វើបែបនេះ គឺសមស្របបំផុត។ ការធ្វើឱ្យសិស្សទាំងអស់គ្នាបានលេងជាមួយគ្នា ជាទូទៅនឹងធ្វើឱ្យកើតមាននូវភាពសប្បាយរីករាយក៏ដូចជាម៉ូតសក់ផងដែរ។

ប្រសិនបើអាច អ្នកអាចថតមុខរបស់សិស្សទាំងអស់គ្នា។ រូបថតទាំងនេះអាចត្រូវព្រីនចេញ ហើយប្រើប្រាស់សម្រាប់ជាការរចនាចុងក្រោយចំពោះម៉ូតសក់។ ភាពអាចធ្វើបានផ្សេងមួយទៀត គឺឱ្យសិស្សទាំងអស់គ្នាធ្វើការអនុវត្តនៅក្នុងបន្ទប់កុំព្យូទ័រ ដើម្បីផាត់ពណ៌ ឬប្រើកម្មវិធី គូរផ្សេងទៀត ដើម្បីធ្វើការរចនានូវម៉ូតរបស់ពួកគេ។

កម្មវិធីកុំព្យូទ័រដែលល្អមួយអាចមាននៅក្នុងគេហទំព័រ ៖
http://download.cnet.com/Hair-Stylist/3000-31713_4-10456029.html

ការនិយាយអំពីម៉ូតសក់របស់ខ្លួន និងអ្វីផ្សេងទៀត ដែលសំខាន់បែបសង្គម និងអារម្មណ៍ សម្រាប់សិស្សហើយវាក៏សំខាន់ណាស់ផងដែរ ដើម្បីជៀសវាងពីការវិនិច្ឆ័យ និងការបញ្ជាក់ ណាមួយ ចំពោះសិស្សដទៃទៀត ហើយសំខាន់គឺការមានម៉ូតសក់ផ្ទាល់ខ្លួន ដែលផ្ដល់ឱ្យអ្នកដទៃទៀតនូវឱកាសដើម្បីធ្វើការព្យាយាម និងស្វែងរកម៉ូតសក់រៀងៗខ្លួន ដោយមិនមានការវិនិច្ឆ័យពីពួកគេ ឬការនិយាយអាក្រក់ពីពួកគេ។









# មេរៀនទី ៥: ម៉ូតសក់ខ្ញុំ - ម៉ូតសក់អ្នក

🕑 រយៈពេលបង្រៀន: ២ ម៉ោង

☑ ការត្រៀមលក្ខណៈ:

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវនឹងការបង្រៀនដែរឬទេ ?
- សរសេរសំណួរសិក្សាលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- រូបគំនូរដែលបានមកពីសិស្ស
- ក្រដាស A4 ពណ៌បៃតង និងលឿង
- ផ្ទាំងរូបភាពម៉ូតសក់ប្លែកៗគ្នា។

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- ប្រៀបធៀបពីម៉ូតសក់ ដែលខុសប្លែកគ្នាជាច្រើន និងពិនិត្យមើលពីភាពខុសគ្នា និងដូចគ្នា
- ផ្តល់មតិរិះគន់វិជ្ជមាននិងមានប្រយោជន៍ លើលទ្ធផលដែលទទួលបានពីអ្នកដទៃ
- ចាត់តាមផ្នែកនៃម៉ូតសក់មរយៈចរិតលក្ខណៈសាមញ្ញៗ។

**សេចក្តីផ្តើម** ៖ ការក្រឡេកមើលទៅក្រោយវិញ 🕑 ៣០ នាទី

👄 ថ្ងៃនេះយើងទាំងអស់គ្នាក្រឡេកមើលរូបគំនូរខុសៗគ្នាជាច្រើន។ យើងនឹងធ្វើបែបនេះព្រោះមានទាំងយុទ្ធសាស្រ្តក្នុង"ការផ្តល់មតិរិះគន់ និងការសរសើរ" ដែលខ្ញុំចង់ឱ្យ អ្នកទាំងអស់គ្នាធ្វើការបង្ហាញពីរូបគំនូររបស់អ្នក នៅកន្លែងណាក៏បានក្នុងថ្នាក់រៀនរបស់យើង។ រូបគំនូរទាំងនោះអាចព្យួរនៅលើជញ្ជាំងឬក៏ដាក់នៅកន្លែងណាផ្សេងក៏បាន ដែលការធ្វើបែបនោះ គឺជាការសម្រេចចិត្តរបស់អ្នក។

✋ ឱ្យសិស្សទាំងអស់ប្រើស្កុតដើម្បីបិទភ្ជាប់ទៅនឹងក្រដាសរបស់ពួកគេ។ ធ្វើការលើកសរសើរ សិស្សទាំងឡាយណាដែលនៅមានភាពស្ទាក់ស្ទើរ ឬក៏គូរគំនូរមិនសូវល្អ ដោយនិយាយថា គំនូររបស់ពួកគេមើលទៅល្អណាស់។

👄 ការផ្តល់មតិរិះគន់ និងការសរសើរ គឺមានន័យថារាល់ការកត់សម្គាល់អវិជ្ជមាន ឬក៏សំណួរទាំងឡាយណាដែលអ្នកបានផ្តល់ឱ្យ គឺគួរតែមានការកត់សម្គាល់ជាវិជ្ជមានផងដែរ។

❓ ហេតុអ្វីបានជាមានសារៈសំខាន់ក្នុងការផ្តល់ការកត់សម្គាល់ជាវិជ្ជមាន ?

(ការធ្វើបែបនេះ គឺជាការលើកទឹកចិត្តដល់សិស្សគ្រប់គ្នា បើមិនដូច្នោះទេពួកគេអាចមាន អារម្មណ៍ក្រៀមក្រំឬក៏អាម៉ាស់

មុខ ឬអាចគិតថាការងាររបស់ពួកគេ គឺមិនសូវល្អគ្រប់គ្រាន់។ វា ក៏ផ្តល់ជាការលើកកម្លាំងចិត្តដល់ទំនាក់ទំនងផ្នែកសុខភាពផងដែរ ដែលមនុស្សជាច្រើន កំពុងតែស៊ាំទៅនឹងការផ្តល់មតិរិះគន់នៅក្នុងមធ្យោបាយវិជ្ជមាន។ ចុងក្រោយ វាធ្វើឱ្យមនុស្សទាំងអស់នោះ មានមោទនភាពចំពោះអ្វីដែលពួកគេបានធ្វើ ដោយសារតែការងារ និងស្នាដៃរបស់ពួកគេ គឺត្រូវបានធ្វើការអង្កេតមើលពីអ្នកដទៃនៅក្នុងបរិយាកាសបែបលើកទឹកចិត្ត)។

រាល់ក្រុមដែលមានសមាជិក៦នាក់ទទួលបានក្រដាសA4 ពណ៌បៃតងចំនួន៣សន្លឹកនិងពណ៌លឿងចំនួន៣សន្លឹក។ បើអ្នកមិនមានពណ៌គ្រប់គ្រាន់ អ្នកអាចទុកវាឱ្យនៅពណ៌សដដែល ហើយប្រើតែសញ្ញាសម្គាល់ក៏បាន។

ការប្រើប្រាស់ពណ៌ខុសៗគ្នា គឺមើលទៅល្អ ប៉ុន្តែចូរជៀស វាងការប្រើពណ៌ក្រហម ដោយសារតែពណ៌នេះបង្ហាញអត្ថន័យអវិជ្ជមាន("ខុស បញ្ឈប់")។

អ្នកអាចកាត់ក្រដាសទាំងអស់ឱ្យទៅជាប័ណ្ណតូចៗ។ ក្រដាសA4មួយសន្លឹក ត្រូវកាត់ឱ្យបានប័ណ្ណចំនួន១០សន្លឹកតូចៗ។ សិស្សគ្រប់គ្នាទទួលបានប័ណ្ណពណ៌បៃតង ចំនួន៥សន្លឹក និងពណ៌លឿងចំនួន៥សន្លឹក។

នៅលើប័ណ្ណពណ៌បៃតង អ្នកទាំងអស់គ្នាត្រូវសរសេរមតិរិះ គន់បែបវិជ្ជមាន ហើយចំណែកឯនៅលើក្រដាសពណ៌លឿងវិញអ្នកទាំងអស់គ្នាត្រូវសរសេរ *សំណួរមួយ* ស្តីអំពីរូបគំនូរទាំងនោះ *ឬក៏ការណែនាំមួយ*។

តើនរណាដែលអាចឱ្យមតិរិះគន់វិជ្ជមានមួយបាន? ឧទាហរណ៍ៈ ខ្ញុំចូលចិត្តពណ៌សក់របស់ អ្នកហើយរូបគំនូរនេះពិតជាគួរបានល្អ។ ចំណែកម៉ូតសក់នេះក៏សមទៅនឹងអ្នកផងដែរ។

តើនរណាដែលអាចផ្តល់សំណួរមួយបាន? ឧទាហរណ៍ ៖ តើសម្លៀកបំពាក់ទាំងនេះបង្ហាញ ពីបុគ្គលិកលក្ខណៈអ្វីខ្លះរបស់អ្នក ឬ ប្រសិនជាអាច តើអ្នកអាចកាត់សក់របស់អ្នកតាមម៉ូតនោះបានដែរឬទេ?

អ្នកទាំងអស់គ្នាអាចសរសេរជាដំបូន្មានមួយនៅលើប័ណ្ណនោះផងដែរ។ ឧទាហរណ៍ ៖ វាពិតជាល្អណាស់ប្រសិនបើអ្នកពាក់ក្រវិលពណ៌បៃតង ដែលស៊ីគ្នាជាមួយនឹងម៉ូតសក់បែបនោះ ឬក៏ អ្នកអាចធ្វើសក់ឱ្យវែងជាងនេះបន្តិច។

នៅថ្ងៃនេះ យើងនឹងនាំគ្នាទៅទស្សនាសារមន្ទីរម៉ូតសក់មួយ ហើយអ្នកទាំងអស់គ្នាត្រូវពិនិត្យ មើលនូវម៉ូតសក់ខុសៗ គ្នាទាំងនោះ។ អ្នកអាចដាក់ប័ណ្ណពណ៌បៃតងចំនួនមួយសន្លឹក និងពណ៌លឿងចំនួនសន្លឹកសម្រាប់រូបគំនូរ មួយ ហើយចំណែកឯប័ណ្ណដទៃទៀត ត្រូវបានដាក់សម្រាប់រូបផ្សេងៗទៀត។

ឱ្យសិស្សដើរជុំវិញ ហើយផ្តល់មតិរិះគន់ និងការសរសើរ។ ប្រហែលជាអ្នក ចាំបាច់ ត្រូវតែជួយពួកគេបន្តិចបន្តួចផងដែរ ជាមួយនឹងសំណួរ ក៏ដូចជាដំបូន្មាននានា។ ប័ណ្ណទាំងអស់ នេះអាចដាក់នៅជាប់នឹងរូបគំនូរទាំងនោះ។

**សកម្មភាពសំខាន់។** : មតិរិះគន់ ៣០ នាទី

ឥឡូវនេះអ្នកទាំងអស់គ្នាអាចត្រឡប់ទៅរករូបគំនូររបស់ពួកគេវិញ ហើយនាំគ្នាពិនិត្យមើលនូវ ការសរសើរ ក៏ដូចជាការផ្តល់មតិរិះគន់ជាច្រើន។ ប្រសិនបើមានសំណួរ ឬដំបូន្មានផ្សេងៗ យើងក៏នឹងឆ្លើយនឹងពួកគេពួកគេផងដែរ។ បន្ទាប់ពីក្រឡេក មើលទៅលើរូបគំនូរនោះរួចហើយ អ្នកក៏អាច ទៅមើលរូបគំនូររបស់អ្នកដទៃផងដែរ ដែលអ្នកអាចមានសំណួរ

ទៅលើរូបទាំងនោះ។ អ្នក ដែលគូរគំនូរនោះ ត្រូវព្យាយាមឆ្លើយនូវសំណួរទាំងនោះ។ ប្រសិនបើអ្នកចង់ធ្វើឱ្យកាន់តែច្បាស់ថែមទៀតពីដំបូន្មាន ឬការសរសើរ ដូច្នេះសូមទៅមើលរូបគំនូរនោះ ហើយប្រាប់សិស្សដែលបានគូរវា។

សិស្សទាំងអស់គ្នាត្រូវនាំគ្នាក្រឡេកមើលមតិរិះគន់ទាំងអស់ ដែលនៅជាប់នឹងរូបគំនូរ។ លើកទឹកចិត្តពួកគេឱ្យធ្វើការពន្យល់អំពីមតិរិះគន់ទាំងឡាយ ដែលពួកគេបានផ្ដល់ឱ្យសិស្សដទៃ និង ត្រូវធ្វើការបញ្ជាក់ឱ្យច្បាស់នូវដំបូន្មានជាច្រើនសម្រាប់សិស្សដទៃទៀត។ បន្ទាប់ពីធ្វើចប់រួចរាល់ ចូរធ្វើការប្រមូលផ្តុំសិស្សទាំងអស់។



តើដំបូន្មានអ្វីដែលអ្នកចូលចិត្តចំពោះរូបគំនូររបស់អ្នក?
តើសំណួរមួយណា ដែលអ្នកគិតថាជាសំណួរល្អ?
តើការសរសើរមួយណា ដែលអ្នកចូលចិត្ត?

ចំពោះកិច្ចការចុងក្រោយបង្អស់ ដែលទាក់ទងទៅនឹងរូបគំនូររបស់យើង គឺត្រូវធ្វើ ការសម្រេចចិត្តថា តើយើងចង់ផ្លាស់ប្តូរអ្វីផ្សេងទៀតទេចំពោះរូបគំនូរនេះ ដោយ ផ្អែកទៅលើមតិ រិះគន់ពីអ្នកដទៃ។ ប្រសិនបើយើងចង់ធ្វើដូច្នោះ អ្នកទាំងអស់គ្នាអាចធ្វើបាន នៅពេលឥឡូវនេះ ហើយប្រសិនបើអ្នកចង់ធ្វើឱ្យវា មើលទៅកាន់តែល្អស្អាត អ្នកក៏អាចធ្វើដូច្នោះផងដែរ។ យើង មិនមានពេលវេលាច្រើននោះទេ ដូច្នេះចំពោះការធ្វើរូបគំនូរឱ្យកាន់តែធំ ឬស្អាត គឺអ្នកទាំងអស់គ្នាអាចយកទៅធ្វើនៅផ្ទះបាន។

ចុងក្រោយ ខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នាប្រើប្រាស់ផ្ទៃជញ្ជាំងធំមួយ ដើម្បីឱ្យរូបគំនូរទាំងនោះ មើលទៅកាន់តែធំ។ ខ្ញុំត្រូវការសិស្សមួយចំនួនដើម្បីជួយខ្ញុំផងដែរ ហើយព្យាយាមស្វែងរកនូវផ្ទៃកជាច្រើននៅក្នុងម៉ូតដែលខុសៗគ្នា។ យើងនឹងដាក់ពួកវាជាមួយគ្នា។

តើនរណាដែលបាននឹកឃើញនូវឧទាហរណ៍ល្អនៃប្រភេទមួយ?

ចំពោះការចាត់ជាផ្នែកអាចជា៖ សក់វែង សក់កន្ទុយអណ្តើក សក់បះ សក់ពណ៌ គ្មានសក់ សក់ពណ៌ឆើតឆាយ សក់រួញ។ ឱ្យសិស្សទាំងអស់ធ្វើការសម្រេចចិត្តថា តើប្រភេទណាមួយ ដែលមាន ហើយចុងក្រោយដាក់ពួកវាឱ្យនៅជាប់គ្នាលើជញ្ជាំង។

## បញ្ចប់មេរៀន

៣០ នាទី

យើងនឹងត្រូវការនរណាម្នាក់ ដើម្បីធ្វើការជ្រើសរើសយកសិស្សណាម្នាក់ ក្នុងចំណោមសិស្ស ដទៃទៀតហើយទុកនៅក្នុងចិត្ត។ ចំណែកឯសិស្សដទៃទៀត ត្រូវធ្វើការទស្សន៍ទាយថា តើបុគ្គលមួយណាដែលត្រូវបានគេជ្រើសរើស។ ពួកគេអាចធ្វើដូច្នេះបានដោយការសួរសំណួរ អំពីសម្លៀកបំពាក់ រូបរាងខាងក្រៅ ការកំសាន្តសប្បាយនិងពីរបៀបក្នុងការមើលទៅកាន់ គាត់/នាង។

ឧទាហរណ៍៖ តើជាសិស្សប្រុសឬ? តើគាត់ខ្ពស់ឬ? តើនាងមានសក់ពណ៌លឿងទុំឬ? តើនាងពាក់ស្បែកជើងប្រជេះឬ? តើគាត់ចូលចិត្តលេងអុកដែរឬទេ?

សិស្សនៅក្នុងថ្នាក់ទាំងអស់ ក៏អាចសួរសំណួរជាច្រើន ដែលអាចឆ្លើយថា "បាទ/ ចាស" "ទេ" ឬ "ប្រហែល"។ ចំពោះសិស្សដែលស្ថិតនៅខាងមុខថ្នាក់ គឺអាចប្រើពាក្យតែ ៣នេះទេ ជាចម្លើយរបស់ពួកគេ ហើយមិនត្រូវប្រើពាក្យអ្វីផ្សេងនោះទេ។

ប្រសិនបើមានសិស្សម្នាក់ ស្គាល់ច្បាស់ថា បុគ្គលនោះជានរណា ដូច្នេះគាត់អាចក្រោកឈរឡើង ហើយនិយាយឈ្មោះតែម្តង។ ប្រសិនបើសិស្សម្នាក់នោះឆ្លើយខុស នោះគាត់/នាង មិនអាចលេងល្បែងនោះតទៅទៀតបានទេ ដូច្នេះអ្នកទាំងអស់គ្នាត្រូវតែគិតដោយប្រុងប្រយ័ត្ន។ ប្រសិនបើគាត់/នាងឆ្លើយត្រូវ ពេលនោះពួកគេនឹងក្លាយទៅជាបុគ្គលម្នាក់ដែលមានសិស្សម្នាក់ ផ្សេងទៀតនៅក្នុងចិត្តរបស់គាត់/នាង។

លេងល្បែងនេះជាមួយនឹងសិស្សទាំងអស់គ្នា។

ចំពោះសិស្សទាំងឡាយណា ដែលចង់យកគំនូរម៉ូតសក់របស់ពួកគ ទៅធ្វើការផ្លាស់ប្តូរបន្តិច បន្តួចនៅផ្ទះ ដូច្នេះពួកគេអាចយកទៅបាន។

## សេចក្តីណែនាំគ្រូ

ប្រសិនបើអ្នកមិនមានក្រដាសពណ៌ អ្នកអាចឱ្យសិស្សទាំងអស់គូររូបស្នាមញញឹម សម្រាប់ការកត់សម្គាល់មតិរិះគន់វិជ្ជមាន និងសំណួរទាំងឡាយនូវដំបូន្មាន ក៏ដូចជាសំណួរជាច្រើនទៀត។

# មេរៀនទី ៦: កន្ត្រៃ និងការកាត់សក់

🕑 រយៈពេលបង្រៀនៈ ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ប្រសិនបើមិនមានកន្ត្រៃ អ្នកអាចប្រើបន្ទះឬស្សី ហើយយកវាធ្វើជាកន្ត្រៃ
- យ៉ាងហោចណាស់មានកន្ត្រៃមួយសំណុំ និងសម្លៀកបំពាក់ដើម្បីធ្វើការបង្ហាញ សិស្សទាំងអស់
- ក្រដាសតូចពណ៌ស ដែលសិស្សអាចប្រើប្រាស់ដើម្បីធ្វើជាប៉េងប៉ោងអក្ខបទ
- ឯកសារ៦.១សម្រាប់សិស្ស និងល្បែងបិទភ្នែក នៅពេលដែលអ្នកធ្វើការសម្រេចចិត្តធ្វើសកម្មភាពណាមួយ។

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- បង្ហាញពីជំហានបន្តបន្ទាប់នៅពេលកាត់សក់
- ដឹងពីបទពិសោធន៍ដែលបានមកទស្សនកិច្ចនៅហាងកាត់សក់

**សេចក្ដីផ្ដើម** ៖ ការក្រឡេកមើលទៅក្រោយ 🕑 ១៥ នាទី

◈ តើអ្នកទាំងអស់គ្នាមានចាំពីរបៀបសម្អាតសម្ភារៈរបស់អ្នកដែរឬទេ? តើអ្នកណាអាច ប្រាប់ខ្ញុំបានពីវិធីធ្វើឱ្យកន្ត្រៃមុតបានល្អ? ជាងកាត់សក់ម្នាក់ គឺប្រើប្រាស់កន្ត្រៃខុសៗគ្នាជាច្រើន។ ដំបូង គឺមានកន្ត្រៃធម្មតាមួយ សម្រាប់ កាត់សក់។ (បង្ហាញឧទាហរណ៍) កន្ត្រៃនេះ គឺមានផ្លែមុត ហើយមានរង្វង់ជុំវិញសម្រាប់ដាក់ម្រាមដៃចូល ដែលធ្វើឱ្យយើងក្ដាប់ដៃបានរឹងមាំល្អ។ ចំណែកឯកន្ត្រៃផ្សេងទៀត គឺហៅថាកន្ត្រៃសាប់។

តើអ្នកគិតថា កន្ត្រៃនេះត្រូវបានបង្កើតឡើងសម្រាប់ប្រើនៅកន្លែងណា?

👄 កន្ត្រៃសាប់ គឺមិនកាត់សក់ទាំងអស់ ដែលមាននៅចន្លោះប្លែកន្ត្រៃនោះទេ។ វាកាត់តែសក់មួយ ដុំៗ ដែលធ្វើឱ្យសក់របស់អ្នកកាន់តែស្តើង។

ថ្ងៃនេះយើងនឹងធ្វើការអនុវត្តពីរបៀបកាន់កន្ត្រៃ។ នេះជាការធ្វើធម្មតា ដោយប្រើដៃ ជាមួយនឹងដៃស្ដាំកាន់កន្ត្រៃ ហើយចំណែកឯដៃម្ខាងទៀត គឺកាន់ក្រាស។



មុនពេលដែលយើងអាចកាត់សក់បាន យើងទាំងអស់គ្នាចាំបាច់ត្រូវតែធ្វើឱ្យសក់រាបស្មើ សិន។ ដូច្នេះយើងនឹងប្រើក្រាសដើម្បីសិតសក់។

បង្ហាញក្រាសមួយ ហើយធ្វើការពន្យល់អំពីគោលបំណងនៃការសិតសក់។ ចាប់ផ្តើមបង្ហាញសិស្សអំពីការសិតសក់ដោយធ្វើជាគំរូនៃម៉ូតណាមួយ សម្រាប់ធ្វើការសង្កេតមើល។ **ចំពោះការសិតសក់មាន ៣ ដំណាក់កាលមុនពេលចាប់ផ្តើមធ្វើការកាត់សក់**៖ ការសិតសក់ ដើម្បីធ្វើឱ្យវារាបស្មើ គឺអាស្រ័យទៅលើម៉ូតដែលអតិថិជនចង់បាន។ **នៅអំឡុងពេលកាត់សក់**៖ ការសិតសក់ឱ្យត្រង់ គឺដើម្បីតម្រឹមវា (ប្រើក្រាសតូច ឬធំ អាស្រ័យ ទៅតាមទំហំរបស់សក់)។

ប្រាប់សិស្សថា ការធ្វើឱ្យសក់ត្រង់ គឺត្រូវធ្វើច្រើនដងជាងការធ្វើផ្សេងៗទៀត រហូតដល់ការកាត់សក់បានបញ្ចប់។ ចំណែកឯការសិតសក់ និងការកាត់សក់ គឺត្រូវធ្វើមួយជំហានម្តងៗ ដូចជានៅផ្នែកខាងស្តាំ ខាងឆ្វេង ខាងក្រោម និងខាងមុខ។ **បន្ទាប់ពីកាត់សក់រួច**៖ សិតសក់ បន្ទាប់ពីកាត់សក់ និងកោររួចដោយការជ្រើមទឹកបន្តិចនៅលើសក់។

## សកម្មភាពសំខាន់។

៦០ នាទី

នៅក្នុងម៉ោងនេះ អ្នកទាំងអស់គ្នាអាចស្នើជាងកាត់សក់ឱ្យជួយអ្នកក្នុងការបង្ហាញពីរបៀបកាត់សក់។ សិស្សទាំងអស់គ្នាអាចបង្កើតជាក្រុមដែលមានគ្នា៤នាក់ផងដែរ។ សិស្សម្នាក់ គឺជាអ្នក ដែលឱ្យគេកាត់សក់ឱ្យអាចអង្គុយនៅលើកៅអី។

ចំណែកឯសិស្សដទៃទៀត គឺជាជាងកាត់សក់ ដែលធ្វើការអនុវត្តនូវជំហានខុសៗគ្នាជាច្រើន។ ប្រសិនបើមិនមានជាងកាត់សក់ជួយក្នុងការបង្ហាញនេះទេ អ្នកទាំងអស់គ្នាអាចធ្វើការអនុវត្ត តាមជំហានជាច្រើន ដែលមាននៅក្នុង *សេចក្តីណែនាំគ្រូ* ដើម្បីផ្តល់ជាការណែនាំសាមញ្ញមួយ។ បន្ទាប់ពីការណែនាំនេះ អ្នកទាំងអស់គ្នាអាចចាប់ផ្តើមអនុវត្តបន្តបានជាមួយនឹងមេរៀន ដែលមានជម្រើសជាច្រើននៅខាងក្រោមនេះ។ *ជម្រើស (នៅពេលដែលគ្មានជាងកាត់សក់មកធ្វើការបង្ហាញពីរបៀបក្នុងការកាត់សក់ និងផ្តល់ជាដំបូន្មានដល់សិស្ស)*។

ផ្តល់ឯកសារ ៦.១សម្រាប់សិស្ស ទៅឱ្យក្រុមទាំងអស់ដែលមានគ្នា៦នាក់។

នៅលើឯកសារសម្រាប់សិស្សនេះ អ្នកទាំងអស់គ្នាឃើញមានជាងកាត់សក់ ដែល ភ្ញៀវម្នាក់ត្រូវ បានអញ្ជើញមកហើយចាប់ផ្តើមកាត់សក់របស់គាត់។ ដូចបានបង្ហាញនៅក្នុងឯកសារដែល ចែកឱ្យរាល់ក្រុមទាំងអស់ ដូច្នេះខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នាប្រើវានៅក្នុងរឿងមួយ។ អ្នកទាំងអស់គ្នាអាចបង្កើតជា *រឿងកំប្លែងផ្ទាល់ខ្លួនមួយ ជាមួយនឹងប៉ោងប៉ោងអត្ថបទ*

ហើយធ្វើការច្នៃប្រឌិតនូវ រឿងអ្វីមួយ ដែលកើតឡើងនៅក្នុងហាងកាត់សក់។ នេះអាចជា រឿងពិត រឿងសំណើច រឿងចម្លែក។ អ្នកព្រមទាំងក្រុមរបស់អ្នក ត្រូវធ្វើការសម្រេចចិត្តថា តើរឿងមួយណា ដែលអ្នកនឹង បង្កើតឡើង។ ខ្ញុំនឹងសរសេរពាក្យមួយចំនួននៅលើក្តារខៀន ដែលអ្នកទាំងអស់គ្នាត្រូវប្រើវា។




✎ សម្លៀកបំពាក់ កន្លែងអង្គុយ កន្ត្រៃសាប់ ជក់ ម៉ូត ដង្កៀប

✋ ឱ្យសិស្សទាំងអស់គ្នានឹកគិតអំពីរឿងមួយហើយឱ្យពួកគេនូវក្រដាសមួយចំនួន ដើម្បីធ្វើជាប៉ោងប៉ោងអត្ថបទ ឬសម្ភារៈបន្ថែម។

## បញ្ចប់មេរៀន

🕑 ១៥ នាទី

✋ ឱ្យសិស្សទាំងអស់ចាប់ផ្តើមធ្វើការនៅក្នុងក្រុមរបស់ពួកគេ ដើម្បីបង្កើតជារឿងសំណើចមួយ ដែលស្តីអំពីក្មេងប្រុសម្នាក់នៅក្នុងហាងកាត់សក់។ ប្រសិនបើពួកគេគិតថា ការធ្វើដូច្នោះមាន លក្ខណៈពិបាក អ្នកអាចជួយពួកគេបានដោយធ្វើការសួរសំណួរមួយចំនួន។

◈ តើក្មេងប្រុសនោះមានឈ្មោះអ្វី?
តើក្មេងប្រុសនោះចង់បានម៉ូតសក់អ្វី?
តើនៅក្នុងរូបភាពទី១ ជាងកាត់សក់ចង់និយាយពីអ្វី? ឱ្យសិស្សកត់វាចូល។
តើបន្ទាប់មកទៀតមានអ្វីកើតឡើង?
តើក្រុមមួយណាដែលចង់ប្រាប់ទៅកាន់ក្រុមដទៃ នូវរឿងរបស់ពួកគេ?

👄 ប្រសិនបើអ្នកមានពេលវេលា អ្នកក៏អាចលេងល្បែង "តើវាជានរណា?"ម្តងទៀតបាន។ ល្បែង នេះគឺនិយាយពីឈ្មោះសិស្សដទៃទៀត ដោយការប៉ះសក់ និងមុខរបស់ពួកគេ។

# សេចក្ដីណែនាំគ្រូ

នៅក្នុងមេរៀននេះយើងបានបង្រៀនសិស្ស ពីរបៀបរៀបចំសម្រាប់ការកាត់សក់ និងរបៀប កាន់កន្ត្រៃ ក្រាស និង កន្ត្រៃគុងដឺ។ ទាំងអស់នេះគួរតែត្រូវបានបង្ហាញ ដោយជាងកាត់សក់ដែល មានបទពិសោធន៍។

អ្នកក៏អាចអញ្ជើញជាងកាត់សក់ ឱ្យធ្វើការបង្ហាញនៅក្នុងសាលាបានផងដែរ។ យើងចង់ស្នើឱ្យជាងកាត់សក់ ធ្វើការកាត់សក់សិស្សម្នាក់ជាគំរូក្នុងចំណោម សិស្សទាំងអស់ ។នៅពេលកាត់សក់ ជាងកាតសក់ត្រូវធ្វើការពន្យល់បណ្ដើរនិងកាត់សក់បណ្ដើរតាមជំហានជាច្រើនដូចខាងក្រោម ៖

១. ស្វាគមន៍ភ្ញៀវ ហើយសួរថា តើគាត់ចង់បានម៉ូតសក់ដូចម្ដេចដែរ។

២. ជាងកាត់សក់គ្របសម្លៀកបំពាក់ភ្ញៀវ ដោយគាបលើកំណាត់គ្រប ហើយលាបម្សៅ កៅអីអង្គុយត្រូវតែមាំ។ ដោះឡេវអាវខាងលើរបស់ភ្ញៀវ ហើយប្រលាត់កអាវចេញមកខាងក្រៅ។ បន្ទាប់មកគ្របកំណាត់មួយផ្ទាំងពីខាងក្រោយនៅលើស្មារបស់គាត់ រួចហើយគ្របកំណាត់ធំមួយផ្ទាំងទៀតពីខាងមុខ។ កុំគ្រវែងកំណាត់នោះលើក្បាលរបស់ភ្ញៀវ ប៉ុន្តែយកកំណាត់នោះទៅខាងមុខភ្ញៀវវិញ ហើយប្រើដៃទាំង២ដើម្បីទាញជាយកំណាត់យកមកគាបដង្កៀបចូលគ្នា។





៣. សក់របស់សិស្សត្រូវសិត ដើម្បីឱ្យវារាប។ ប្រសិនបើសក់ស្ងួតពេក យើងអាចបាញ់ទឹកឱ្យសក់សើមបន្តិច។ យើងក៏អាចប្រើក្រាសខុសគ្នាបានផងដែរ។ សក់ត្រូវសិតវាឱ្យទៅផ្នែកម្ខាង ដើម្បីងាយស្រួលកាត់។

៤.ជំហានបន្ទាប់ គឺត្រូវប្រើម្សៅ។ វិធីក្នុងការលាបម្សៅ ៖

*តើយើងត្រូវលាបម្សៅដោយវិធីណា ? សម្រាប់ជាងកាត់សក់ តើគុណប្រយោជន៍របស់ម្សៅមានអ្វីខ្លះ ?*

យើងត្រូវលាបម៉្សៅនៅជុំវិញក ដើម្បីឱ្យជាងកាត់សក់ងាយស្រួលពិនិត្យមើលថា តើកន្លែងណាខ្លះដែលបានកាត់រួច និងកន្លែងណាដែលមិនទាន់កាត់។ បន្ថែមពីនេះ ទៅទៀត យើងក៏អាចឃើញផងដែរថា តើសក់របស់យើងវាស្មើល្អដែរឬទេ ហើយនៅពេលដែលសក់ផ្នែកខាងមុខមិនទាន់បានកាត់ស្មើល្អ យើងក៏អាចមើលឃើញវា ដោយម្សៅទាំងអស់នេះផងដែរ ដូច្នេះហើយយើងក៏អាចតម្រឹមវាបន្ថែមទៀតផងដែរ។

គុណប្រយោជន៍របស់ម្សៅ នៅក្នុងការជួយជាងកាត់សក់ ៖

- លាបម្សៅនៅលើកន្ត្រៃជួយឱ្យវារអិលស្រួលកាត់
- លាបម៉្សៅនៅលើជើងសក់ធ្វើឱ្យជើងសក់កាន់តែរឹង ហើយងាយស្រួលកោរ
- លាបម្សៅនៅលើមុខ គឺធ្វើឱ្យយើងអាចមើលឃើញនូវផ្នែកដែលបានកាត់រួច និងមិនទាន់កាត់។

៥. ឥឡូវនេះការកាត់សក់ដោយប្រើកន្ត្រៃពិត និងកន្ត្រៃគុងដីអាចចាប់ផ្តើមបាន។
មានកន្ត្រៃគុងដីអគ្គិសនីផងដែរ ប៉ុន្តែនៅតាមជនបទជាងកាត់សក់ជាច្រើនប្រើវាដោយដៃ ។ ទាក់ទងទៅនឹងការប្រើកន្ត្រៃប្រភេទនេះ អ្នកនឹងត្រូវការជាងកាត់សក់ម្នាក់ ដើម្បីបង្ហាញពីរបៀបប្រើប្រាស់កន្ត្រៃគុងដីអគ្គិសនីនេះ។

សិស្សកត់ត្រានូវអ្វីដែលគាត់បានពន្យល់ ហើយគាត់ក៏ផ្តល់ជាដំបូន្មានឱ្យសិស្សទាំង អស់គ្នានៅខណៈពេលដែលពួកគេកំពុងអនុវត្ត។



កន្ត្រៃកាត់សក់ទូទៅ



កន្ត្រៃសាប់ ដែលងាយស្រួលស្គាល់ ដោយសារមុខរបស់វាដូចក្រាស



កន្ត្រៃគុងដីប្រើដោយដៃ










# មេរៀនទី ៧: ការថែរក្សាសក់

🕑 រយៈពេលបង្រៀនៈ ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ទឹក (ប្រសិនបើអាច គឺប្រើទឹកក្ដៅ) ផ្តិលទឹកចំនួន១០
- សាប៊ូ ម៉ាស៊ីនត្រជាក់
- ក្រាស ជក់
- កន្សែងចំនួន១០
- ម្សៅ (ប្រសិនបើអ្នកជ្រើសរើសសម្រាប់សម្អាតសក់)

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- បង្ហាញពីជំហានបន្តបន្ទាប់នៅពេលកាត់សម្អាតសក់
- អនុវត្តចំណេះដឹងរបស់ពួកគេពិតៗ ដោយការដើរតួសម្ដែងជាមួយនឹងសិស្សដទៃទៀត

**សេចក្ដីផ្ដើមៈ** ការក្រឡេកមើលទៅក្រោយវិញ 🕑 ១៥ នាទី

👄 នៅក្នុងមេរៀនមុន យើងទាំងអស់គ្នាបានសិក្សាអំពីវិធីដែលយើងគួរតែប្រព្រឹត្ត ប្រសិនបើយើងក្លាយទៅជាជាងកាត់សក់។ នាំគ្នាព្យាយាមធ្វើដូច្នោះទាំងអស់គ្នា។ ធ្វើការជ្រើសរើសសិស្សដទៃទៀតនៅក្នុងថ្នាក់រៀន។ ម្នាក់ក្នុងចំណោមអ្នកទាំងអស់គ្នា គឺជាអតិថិជន ហើយ ចំណែកឯម្នាក់ទៀត គឺជាជាងកាត់សក់។

ចូរធ្វើការអនុវត្តការស្វាគមន៍ភ្ញៀវ ដោយសួរនូវអ្វីដែលគាត់/នាងចង់បាន និងរៀបចំឱ្យ បានត្រឹមត្រូវតាមលំដាប់លំដោយ។

✋ សិស្សទាំងអស់គ្នាកំពុងអនុវត្តការងារដៃគូ។ ពួកគេអាចប្ដូរការសម្ដែងគ្នាបាន។ ស្វែងរកឧទាហរណ៍ល្អណាមួយ ហើយស្នើពួកគេឱ្យធ្វើការបង្ហាញវាទៅកាន់មិត្តរួមថ្នាក់ដែលនៅសល់។

**សកម្មភាពសំខាន់។** 🕑 ៦០ នាទី

👄 ជាការពិតណាស់ វាក៏សំខាន់ផងដែរ ប្រសិនបើអ្នកទាំងអស់គ្នាថែរក្សាសក់ដោយខ្លួនរបស់អ្នក ផ្ទាល់។ នេះគឺមានន័យថា អ្នកត្រូវតែធ្វើការកក់ និងសម្អាតវាឱ្យបានល្អ។ ខ្ញុំគិតថា អ្នករាល់គ្នាប្រាកដជាបានសម្អាតសក់របស់អ្នកបានយ៉ាងទៀងទាត់ ក៏ប៉ុន្តែតើអ្នកបានធ្វើវាតាមរបៀប ត្រឹមត្រូវដែរឬទេ?

❓ តើនរណាដែលគិតថា គាត់/នាងបានធ្វើការសម្អាតសក់តាមវិធីដែលត្រឹមត្រូវ?

👄 ច្បាប់ទី១ស្តីអំពីការសម្អាតសក់របស់អ្នកគឺៈ កុំធ្វើការលាងសម្អាតសក់របស់អ្នក ច្រើនជាងមួយដងនៅរៀងរាល់ ២ ឬ៣ថ្ងៃ។ ខ្ញុំនឹងធ្វើការពន្យល់អ្នកអំពីជំហានមូលដ្ឋាន នៃការសម្អាតសក់របស់ អ្នកទាំងអស់គ្នា។ អ្នកក៏ចាំបាច់ត្រូវធ្វើការកត់ត្រាផងដែរ ដោយសារតែយើង នឹងធ្វើការអនុវត្តវានៅពេលក្រោយ។ ចូរព្យាយាមធ្វើការបែងចែកជាជំហាន ខុសៗគ្នា។

ជ្រើមសក់របស់អ្នក ដោយប្រើទឹកតិចៗ ដើម្បីឱ្យសាប៊ូអាចមានពពុះគ្រប់គ្រាន់។ ព្យាយាមប្រើប្រាស់ទឹកក្តៅឧណ្ហៗនៅពេលលាងជម្រះសក់របស់អ្នក។

ឥឡូវនេះយកសាប៊ូបន្តិច ដែលប្រហែលជាមួយភាគបួននៃប្រអប់ដៃរបស់អ្នក។ អ្នកទាំងអស់គ្នាក៏អាចប្រើសាប៊ូច្រើនជាងនេះផងដែរ ដោយអាស្រ័យទៅលើប្រភេទនៃសក់ដែលអ្នកមាន។ ចាប់ផ្តើមសម្អាតសក់របស់អ្នកចេញពីគល់វាទៅដោយធ្វើបែបនេះរហូតដល់អ្នកឈប់។ ម៉ាស្សា ស្បែកក្បាលរបស់អ្នកថ្នមៗ ដោយប្រើចង្អុលដៃរបស់អ្នកតិចៗ។ ការធ្វើបែបនេះ គឺជាវិធីសាស្ត្រក្នុងការធ្វើឱ្យអារម្មណ៍ធូរស្រាល ដែលនឹងជួយអ្នកសម្អាតបាននូវជាតិខ្លាញ់ដ៏ច្រើន និងផលិតផលសក់ដទៃៗទៀតដែលមាននៅក្នុងសក់របស់អ្នក។

នៅពេលដែលអ្នកបានកក់សក់នឹងសាប៊ូបានយ៉ាងហ្មត់ចត់ហើយ ចូរប្រើប្រាស់ទឹកក្តៅឧណ្ហៗ ដើម្បីលាងជម្រះសាប៊ូ។ ចូរប្រាកដថា អ្នកបានសម្អាតសាប៊ូទាំងនោះចេញអស់ពីក្នុងសក់របស់ អ្នក បើមិនដូច្នោះទេវានឹងធ្វើឱ្យសក់របស់អ្នករអិល និងស្អិតជាប់គ្នា។ បន្ទាប់ពីលាងជម្រះ សាប៊ូរួចរាល់ អ្នកអាចប្រើប្រេងអប់សក់ជាមួយនឹងសក់របស់អ្នក។

ចូរចងចាំថា ប្រេងអប់សក់នោះ មិនគួរប្រើវារហូតដល់គល់សក់នោះទេ។ អ្នកគួរតែចាប់ផ្តើមប្រើវា ប្រហែលជា ២.៥៣៩ សម ទៅខាងក្រោមនៃចន្លោះសក់។ អ្នកអាចប្រើប្រេងអប់សក់នេះ ឱ្យបានច្រើនជាងសាប៊ូបន្តិចក៏បានដែរ ដោយកុំបារម្ភអ្វី ពីព្រោះវាមិនធ្វើឱ្យមានពពុះច្រើនដូចសាប៊ូនោះទេ។ ទុកប្រេងអប់សក់នោះ នៅក្នុងសក់របស់អ្នករយៈពេលប្រហែលជា២ ទៅ៥នាទី។ បន្ទាប់មកធ្វើការលាងសម្អាតវាចេញពីសក់របស់អ្នក ហើយលាងជម្រះសាប៊ូទាំងអស់ចេញពីសក់របស់ អ្នក។ យកម្រាមដៃរបស់អ្នកសិតសក់ ដោយធ្វើចលនាពីលើ ចុះមកក្រោម បន្ទាប់ពីលាងជម្រះប្រេងលាបសក់រួច។ ការធ្វើបែបនេះ គឺមិនធ្វើឱ្យសក់របស់អ្នកជំពាក់ ឬជាប់គ្នាឡើយ។ ឥឡូវនេះចូរលាងសម្អាតសក់របស់អ្នកដោយប្រើទឹកត្រជាក់ម្តង។ ការធ្វើបែបនេះនឹងជួយឱ្យជិតរន្ធសក់របស់អ្នក ហើយក៏ធ្វើឱ្យសក់របស់អ្នកភ្លឺរលោងស្អាតបន្ទាប់ពីវាស្ងួត។

ចូរប្រើកន្សែងមួយដើម្បីជូតសក់របស់អ្នកឱ្យស្ងួត មុនពេលប្រើឧបករណ៍ធ្វើឱ្យស្ងួតដទៃទៀត។ រុំកន្សែងជុំវិញសក់របស់អ្នក ហើយជូតវាសើៗ។ កុំធ្វើចលនាខ្លាំងពេកក្នុងការជូតសក់របស់អ្នក ដោយសារតែការធ្វើបែបនេះ អាចបណ្តាលឱ្យសក់របស់អ្នកជំពាក់គ្នា និង ដាច់សក់ផងដែរ។ អ្នកក៏អាចធ្វើសក់របស់អ្នកឱ្យស្ងួតដោយប្រើខ្យល់ ឬប្រើឧបករណ៍ផ្លុំដើម្បី ធ្វើវាឱ្យមានសណ្តាប់ធ្នាប់។

*ជម្រើស ៖ ប្រសិនបើអ្នកចង់ អ្នកអាចធ្វើការពន្យល់ប្រាប់សិស្សដទៃទៀតអំពីជម្រើស ផ្សេង ៗទៀតក្នុងការសម្អាតសក់របស់អ្នក។ មើលសេចក្ដីណែនាំគ្រូសម្រាប់ចំណុចនេះ។*

តើនរណាអាចប្រាប់ខ្ញុំអំពីជំហានបន្តបន្ទាប់ ដែលអ្នកបានកត់ត្រា?

យើងនឹងធ្វើការអនុវត្តការលាងសម្អាតនេះជាមួយនឹងអ្នកស្ម័គ្រចិត្តមួយចំនួន។ គោលបំណងនៃការធ្វើបែបនេះ គឺដើម្បីអនុវត្តនូវការណែនាំ និងផ្ដល់ជារបាយការណ៍មួយនៃបទពិសោធន៍ របស់អ្នកនៅពេលក្រោយទៅកាន់ក្រុម។ ចំពោះរបាយការណ៍នេះ ត្រូវតែបង្ហាញនូវទិដ្ឋភាពចំនួន ៣។ ១. តើដំណើរការល្អជាអ្វី? ២. តើយើងអាចធ្វើការកែលម្អអ្វីខ្លះ? ៣. តើយើងបានសិក្សាអ្វីខ្លះ? តើមានសិស្សចង់ធ្វើការសម្អាតសក់របស់ពួកគេដែរឬទេ?

បន្ទាប់ពីមានសិស្សស្ម័គ្រចិត្តចំនួន១០នាក់ ដែលគួរតែជាចំនួនមួយគ្រប់គ្រាន់។ សិស្សទាំងអស់បង្កើតក្រុមដែលមានភេទដូចគ្នា និងមានសមាជិក ៣នាក់ក្នុងមួយក្រុម ហើយនាំគ្នាចេញទៅខាងក្រៅ។ ក្រុមនីមួយៗត្រូវជ្រើសរើសយកអ្នកស្ម័គ្រចិត្តមួយរូប ដែលមានភេទដូចគ្នាសន្រាប់កក់សក់ឱ្យ។

គាត់/នាងអាចអង្គុយនៅលើកៅអី ហើយក្បាលត្រូវទ្រេតមកខាងក្រោយ។ សិស្សទាំងអស់ត្រូវធ្វើតាមសេចក្ដីណែនាំដែលបានបង្កើតឡើង។

## បញ្ចប់មេរៀន

១៥ នាទី

ប្រមូលសិស្សទាំងអស់ចូលមកក្នុងថ្នាក់រៀនវិញ។

រាល់ក្រុមទាំងអស់អាចរាយការណ៍ទៅកាន់ក្រុម ៣ដទៃទៀត អំពីបទពិសោធន៍របស់ពួកគេ។ អ្នកត្រូវតែបង្ហាញនូវ ៣ ចំណុច ដែលយើងបានពិភាក្សាគ្នានៅខាងដើម។ វាក៏សំខាន់ផងដែរ ក្នុងការឱ្យអតិថិជនប្រាប់ពីបទពិសោធន៍ជាច្រើនរបស់នាង។ សម្រាប់ក្រុមនីមួយៗ អ្នកត្រូវតែសរសេរនូវចំណុចអ្វីមួយដែលដូចគ្នា និងចំណុចមួយទៀត ដែលខុសគ្នា។

អ្នកទាំងអស់គ្នាអាចជ្រើសរើសដោយខ្លួនអ្នកផ្ទាល់ថា តើក្រុមមួយណាដែលអ្នក ចង់ពិភាក្សាជាមួយ។

ឱ្យសិស្សទាំងអស់គ្នា ចូលរួមនៅក្នុងការចែករំលែកនូវបទពិសោធទាំងនោះ។ នេះអាចធ្វើជា លក្ខណៈក្រៅផ្លូវការ ប៉ុន្តែចូរពិនិត្យមើលថា តើក្រុមទាំងអស់មានបានកត់ត្រាចូលក្នុងបញ្ជីរបស់ពួកគេ *នូវចំណុចដែលដូច និងខុសគ្នា* ដែរឬទេ។ រយៈពេល១០នាទី ក្រោយមកចូរធ្វើ ការប្រមូលផ្ដុំសិស្សទាំងអស់។

តាមរយៈបទពិសោធន៍នេះ តើអ្នកបានរៀនអ្វីខ្លះ?
បន្ទាប់ពីមេរៀននេះតើអ្នកបានធ្វើអ្វី ដែលប្លែកខ្លះ?

នៅក្នុងមេរៀនក្រោយ យើងនឹងស្រាវជ្រាវនូវផលិតផលសក់ជាច្រើនទៀត។ ចំពោះកិច្ចការផ្ទះរបស់អ្នកទាំងអស់គ្នា គឺត្រូវសរសេរចូលនូវផលិតផលប្រើជាមួយសក់ ដែលអ្នកមាននៅ ផ្ទះ។ ប្រសិនបើអ្នកមាន អ្នកក៏អាចយកដបចង់(ទទេ) ឬសម្ភារៈផ្សេងៗទៀត។ *ខ្ញុំនឹងជួបអ្នកទាំងអស់គ្នានៅសប្ដាហ៍ក្រោយ។*

# សេចក្តីណែនាំគ្រូ

មានឱកាសជាច្រើន ដើម្បីធ្វើការសម្អាតសក់របស់អ្នកដោយមិនប្រើសាប៊ូ។ វាក៏ប្រហែលជាគំនិតមួយដ៏ល្អ ដែលត្រូវប្រាប់សិស្សរបស់អ្នកអំពីចំណុចនោះ។ ចំពោះការ ប្រើ សាប៊ូច្រើនពេកអាចធ្វើឱ្យសក់របស់អ្នកស្ងួត ហើយជម្រុះនូវប្រេងធម្មជាតិ ដែលរូបរាងកាយ  របស់អ្នកបានបង្កើតឡើងដើម្បីឱ្យសក់របស់យើងមើលទៅភ្លឺរលោង និងទន់។ ហេតុផលផ្សេងទៀត គឺថាសាប៊ូ ជាជាតិគីមីហើយអាចធ្វើឱ្យប៉ះពាល់ដល់ស្បែករបស់អ្នក។ ចុងក្រោយតែមិន មែនចុងបញ្ចប់ គឺថាសាប៊ូមានតម្លៃថ្លៃ។

ជម្រើសផ្សេងទៀត ដែលសម្អាតសក់របស់អ្នកបានដោយប្រើម្សៅ ។ វាជាការល្អក្នុងការឱ្យសិស្សទាំងអស់ធ្វើការអនុវត្តជាមួយនឹងម្សៅនោះផងដែរ។ ចំណែកឯការណែនាំចំពោះវិធីប្រើប្រាស់វា គឺធម្មតា។

អ្វីដែលអ្នកត្រូវការនោះ គឺ ម្សៅពេញមួយស្លាបព្រាបាយ។ ចាក់ម្សៅនោះនៅលើស្បែកក្បាល របស់អ្នក  ហើយជាពិសេស គឺត្រូវចាក់នៅពីលើសក់តែម្តង។ ម៉ាស្សាស្បែកក្បាលបន្តិច ដើម្បីឱ្យម្សៅទាំងនោះរលាយស្មើគ្នានៅលើក្បាលរបស់អ្នក ។ គ្រវីសក់របស់អ្នកដើម្បីឱ្យអស់ម្សៅទាំងនោះ ហើយជុសរហូតដល់វាអស់ពីលើក្បាល។
អ្នកមិនអាចប្រាប់ពីភាពខុសគ្នារវាងការសម្អាតសក់ "ធម្មតា" ជាមួយនឹងសាប៊ូ និងទឹកពីការ ប្រើម្សៅទាំងនេះ។

ការសម្អាតសក់របស់អ្នកដោយប្រើម្សៅ គឺកាន់តែធ្វើឱ្យសក់មានសុខភាពល្អ ដោយសារតែ ម្សៅមិនត្រឹមតែកម្ចាត់ជាតិខ្លាញ់ចោលនោះទេ ថែមទាំងជាតិប្រេងផងដែរ ហើយក៏មិនធ្វើឱ្យសក់របស់អ្នកសើមផងដែរ។

# មេរៀនទី ៨: ផលិតផលប្រើជាមួយសក់

🕑 រយៈពេលបង្រៀន : ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើល ព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)។

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ក្រដាសA4 សម្រាប់ធ្វើការចាត់ជាផ្នែករបស់ពួកគេ
- ផលិតផលប្រើប្រាស់ជាមួយសក់
- រៀបចំបញ្ជីនៃប្រភេទផលិតផលប្រើជាមួយសក់។

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- ដឹងផលិតផលប្រើជាមួយសក់ទៅតាមប្រភេទនីមួយៗ
- ដឹងអំពីផលិតផល ប្រើធ្វើឱ្យប៉ះពាល់ស្បែកក្បាល

**សេចក្តីផ្តើម:** តើនរណាជាអ្នកដឹកនាំ 🕑 ១៥ នាទី

👄 យើងនឹងនាំគ្នាលេងល្បែងមួយ ដែលមានឈ្មោះថា "នរណាជាអ្នកដឹកនាំ"( *មើលសេចក្តីណែនាំគ្រូ*)។ សិស្សម្នាក់ ចេញពីថ្នាក់រៀនគាត់/នាង គឺជាអ្នកអង្កេតមើល។ ចំណែកឯសិស្សដទៃទៀតធ្វើការជ្រើសរើសអ្នកដឹកនាំម្នាក់។ គាត់/នាង ចាប់ផ្តើមធ្វើសកម្មភាពបន្តិចដែលទាក់ទងទៅ នឹងការ កាត់សក់ ឬការអ៊ុតសក់។

❓ តើអ្នកអាចធ្វើសកម្មភាពអ្វីខ្លះបាន? កាត់សក់ដោយប្រើកន្ត្រៃ ធ្វើម៉ូតសក់របស់ អ្នកឡើងវិញ ជូតសក់របស់អ្នក កោរ សក់សម្អាត។ល។ អ្នកដឹកនាំត្រូវតែធ្វើសកម្មភាពទាំងនោះ រយៈពេលប្រហែលជា១០វិនាទី បន្ទាប់មកជ្រើសរើសយក សកម្មភាពផ្សេងមួយទៀត។ ចំពោះសិស្សដទៃទៀត ត្រូវតែធ្វើតាមអ្នកដឹកនាំរបស់ពួកគេក៏ប៉ុន្តែមិនឱ្យ ក្រឡេកមើល គាត់/នាងទេ។ អ្នកអង្កេតមើលក៏បានត្រលប់មកវិញ ហើយព្យាយាមមើលអ្នកដឹកនាំ ដោយធ្វើការអង្កេត មើលថា តើ នរ ណាដែលចាប់ផ្តើមធ្វើសកម្មភាពពិត។

✋ លេងល្បែងនេះជាមួយនឹងអ្នកដឹកនាំពីរបីនាក់ទៀត។

## សកម្មភាពសំខាន់។

🕑 ៣០ នាទី

អ្នកទាំងអស់គ្នាបានបញ្ចប់កិច្ចការផ្ទះ ហើយក៏បានស្វែងរកនូវផលិតផលរបស់សក់មួយចំនួនទៀតដែរ ដែលមាននៅក្នុងផ្ទះរបស់អ្នក។ ថ្ងៃនេះយើងនឹងបង្ហាញពីផលិតផលទាំងអស់នោះ ហើយពិនិត្យមើលថាតើ យើងអាចចាត់ផលិតផលទាំងនោះទៅតាមផ្នែកយ៉ាងដូចម្តេចដែរ។ ជាដំបូងអ្នកអាចបង្កើតក្រុមដែលមានគ្នា៨នាក់ បន្ទាប់មកគ្រប់ៗគ្នាត្រូវធ្វើតាមជំហាន ដែលមាននៅលើក្តារខៀន។

គ្រាន់តែសរសេរពាក្យដែលមានអក្សរដិត គូសបន្ទាត់ពីក្រោម។

១. គ្រប់ៗគ្នាអានពាក្យមួយណាដែលគាត់/នាងបានសរសេរ។
២. ដាក់ប័ណ្ណទាំងអស់នៅក្នុងក្រុមតែមួយ ចំពោះអ្នកដែលមានផលិតផលដូចគ្នា (ឧទាហរណ៍ៈ គ្រប់គ្នាដែលមានសាប៊ូត្រូវដាក់ប័ណ្ណទាំងអស់ជាមួយគ្នា)
៣. <u>ពិភាក្សា</u> ជាមួយនឹងក្រុមរបស់អ្នកថា តើលក្ខខណ្ឌមួយណាដែលអ្នកនឹងប្រើប្រាស់ ដើម្បីចាត់របស់ទាំងនោះទៅតាមផ្នែក។ ការធ្វើបែបនេះ គឺកាន់តែមានលក្ខណៈពិបាក ដែលលក្ខខណ្ឌអាចមានដូចជាៈ តើយើងប្រើសម្រាប់លាងសម្អាតឬ? តើប្រើសម្រាប់តែក្មេងប្រុសឬ? តើប្រើសម្រាប់ធ្វើឱ្យសក់របស់អ្នកមានពណ៌ឬ? តើប្រើសម្រាប់តុបតែងសក់របស់អ្នកឬ? សិស្សទាំងអស់គ្នាអាចគិតអំពីលក្ខខណ្ឌដោយខ្លួនពួកគេផ្ទាល់ ហើយពួកគេក៏អាចធ្វើការសម្រេចចិត្តក្នុងការដាក់ពណ៌ឱ្យរបស់ទាំងនោះផងដែរ។ រាល់ផលិតផល ដែលមានពណ៌បៃតង ត្រូវដាក់ក្នុងក្រុមជាមួយគ្នា ចំណែកឯពណ៌លឿង។ល។
៤. <u>ចាត់ទៅតាមផ្នែក</u> របស់ផលិតផល។
៥. <u>គិតស្រមៃ</u> ដើម្បីធ្វើវាយ៉ាងណាឱ្យអ្នកដទៃអាចយល់បាន។ នេះមានន័យថាអ្នកត្រូវបង្កើតផែនទីគំនិតមួយ ប៉ុន្តែវាអាចគូររូបផលិតផលទាំងនោះនៅលើក្រដាសធំមួយ ឬក៏គិតពីវិធីផ្សេងដើម្បីធ្វើបទបង្ហាញពីវា។

ឱ្យសិស្សទាំងអស់ចែករំលែកនូវលទ្ធផលរបស់ពួកគេ ហើយអនុវត្តតាមគម្រោងដែល មាននៅលើក្តារខៀន។ ចូរផ្តល់ឱ្យក្រុមនីមួយៗនូវផ្ទាំងក្រដាសធំ ដែលជាតម្រូវការ ក្នុងការបង្ហាញនូវលទ្ធផលរបស់ពួកគេ។

បន្ទាប់ពីការងារទាំងអស់នេះបានចប់សព្វគ្រប់ ក្រុមនីមួយៗអាចធ្វើបទបង្ហាញពីការដាក់ផលិតផលទៅ តាមផ្នែកដល់ក្រុមដទៃទៀត។ ពួកគេទាំងអស់គ្នាក៏អាចពន្យល់ពីកិច្ចសហការគ្នានៅក្នុងដំណើរការក្រុម។ តើអ្នកទាំងអស់គ្នាមានមានជាប់ទាក់ទង នៅក្នុងការជ្រើសរើសប្រធានបទទាំងនេះដែរឬទេ?

## បញ្ចប់មេរៀន

🕑 ១៥ នាទី

ខ្ញុំគិតថា អ្នកទាំងអស់គ្នាគឺជាអ្នកសង្កេតដ៏ល្អ។ ឥឡូវនេះវាដល់ពេលដែលត្រូវធ្វើការសិក្សាពីផលិតផលទាំងអស់នោះហើយ។ មានការចាត់ទៅតាមផ្នែកនីមួយៗជាច្រើន ដែលអាចត្រូវបាន ធ្វើការបង្ហាញ ហើយខ្ញុំក៏បានឃើញវាទាំងអស់រួចហើយ។ ដូច្នេះទុកឱ្យខ្ញុំសរសេរចូលក្នុងបញ្ជី មួយរបស់ផ្នែកទាំងនោះ ដែលខ្ញុំបានរកឃើញនៅក្នុងការស្រាវជ្រាវនេះ។ មួយចំនួននៃប្រភេទ ទាំងអស់នេះ គឺមាននៅក្នុងបញ្ជីរបស់អ្នករួចទៅហើយ។

ជក់/ក្រាស ជាងកាត់សក់ ផលិតផលពណ៌ ប្រេងអប់សក់ ឧបករណ៍សម្រាប់ធ្វើសក់ឱ្យរួញ សម្រាប់អ៊ុតសក់ ធ្វើសក់ឱ្យស្ងួត សម្រាប់បណ្តុះសក់ គ្រឿងតុបតែង សាប៊ូ ក្រមួន/ចាហួយឧបករណ៍សម្រាប់មូរសក់ សម្រាប់ពន្លាសក់បុរស។

? តើនរណាដែលបានឃើញរបស់ម៉្យាង ដែលពួកគេបានកត់ត្រារួចហើយក្នុងបញ្ជីរបស់ពួកគេ?

មានផលិតផលជាច្រើនដែលអ្នកអាចទិញនៅក្នុងហាង ហើយត្រូវបានចាត់ទៅតាមផ្នែកមួយក្នុងចំណោមផ្នែកទាំងអស់នេះ។ ឧទាហរណ៍ ៖ បើខ្ញុំទិញកាំបិតកោរ តើអាចជាប្រភេទ មួយណា? (មនុស្សប្រុស) ហើយចុះប្រសិនបើខ្ញុំ ទិញកន្ត្រៃគុងដឺវិញ? (ជាងកាត់សក់) ផលិត ផលមួយចំនួនអាចសមស្របបាន២ប្រភេទ។ បន្ទាប់មកអ្នកត្រូវធ្វើការជ្រើសរើសថា តើមួយ ណាដែលសមស្របបំផុត។ កិច្ចការបន្ទាប់របស់អ្នកនឹងនិយាយអំពីផលិតផលទាំងពីរនេះ។ អ្នកទាំងអស់គ្នារួមទាំងអ្នកដទៃទៀត គឺនឹងធ្វើការប្រៀបធៀបនូវផលិតផលពីរ ដែលយើងទើប តែបានដាក់វាចូលក្នុងបញ្ជី។ នៅខណៈពេលដែលអ្នកធ្វើការប្រៀបធៀបផលិតផលទាំងនេះ អ្នកត្រូវស្វែងរកថា តើមួយណាដែលល្អបំផុត ហើយនឹករកនូវការពិភាក្សាគ្នាល្អណាមួយ ដើម្បីពន្យល់អំពីចំណុចនេះ។ ដើម្បីណែនាំចំពោះអ្នក តាមរយៈការពិភាក្សាគ្នានេះ អ្នកអាចប្រើឯកសារ ៨.១ សម្រាប់សិស្សបាន។ ថ្ងៃនេះអ្នកទាំងអស់គ្នាអាចចាប់ផ្តើមជាជំហានៗ ដែលមាននៅលើឯកសារសម្រាប់សិស្ស ហើយនៅពេលដែល កំពុងធ្វើកិច្ចការផ្ទះរបស់អ្នក អ្នកទាំងអស់គ្នាអាចរៀបចំការធ្វើបទបង្ហាញរបស់អ្នកនៅក្នុងមេរៀនទី៩ ឬទី១០។

ផ្តល់ឯកសារ៨.១ សម្រាប់សិស្ស ទៅឱ្យសិស្សទាំងអស់គ្នា។

## សេចក្តីណែនាំគ្រូ

ល្បែង "នរណាជាអ្នកដឹកនាំ" គឺត្រូវបានបង្ហាញនៅលើគេហទំព័រ www.ibec.worlded.org។ វាក៏បានធ្វើការពណ៌នានៅក្នុងកូនសៀវភៅតូចៗ ដែលត្រូវបានចែកជូននៅតាមសាលាមួយ ចំនួន។ ធ្វើការពិនិត្យមើលប្រសិនបើអ្នកអាចទទួលបានសៀវភៅនោះមួយក្បាល ប្រសិនបើ អ្នកមិនច្បាស់អំពីល្បែងនោះ។



# ការប្រៀបធៀបផលិតផល

១. ជាដំបូងអ្នកទាំងអស់គ្នាចាំបាច់ត្រូវតែជ្រើសរើសយកផលិតផលមួយប្រភេទ ដែលអ្នកចង់ធ្វើការអង្កេត។ ចំពោះផលិតផលនោះ អ្នកក៏ចង់ដឹងព័ត៌មានបន្ថែមពីវាផងដែរ។

២. ពណ៌នាពីផលិតផលពីរប្រភេទ ដោយយោងទៅតាមការមើលឃើញ នៃគ្រឿងផ្សំនិងរបៀបប្រើ។ អ្នកទាំងអស់គ្នាក៏អាចធ្វើការបន្ថែមផងដែរ ប្រសិនបើអ្នកចង់។ តើអ្នកទាំងអស់គ្នាយល់នូវពាក្យទាំងឡាយ ដែលសរសេរនៅលើដប/ប្រអប់ដែរឬទេ? ប្រសិនបើមិនយល់ ចូរធ្វើការស្រាវជ្រាវបន្ថែម ដោយ សាកសួរម្ចាស់ហាងកាត់សក់ បើកអ៊ីនធឺណែត ឬស្រាវជ្រាវតាមកុំព្យូទ័រ។

៣. បង្កើតជាបញ្ជីដោយបង្ហាញពីភាពខុសគ្នា និងដូចគ្នា ហើយឱ្យអាទិភាពទៅលើភាពខុសគ្នា។ តើមួយណាដែលច្រើនបំផុត ហើយមួយណាដែលតិចបំផុត?

៤. មួយណាដែលគេចាត់ទុកថាល្អបំផុតៈ ងាយស្រួលប្រើ មានប្រសិទ្ធភាព ល្អសម្រាប់បរិស្ថាន មានតម្លៃប្រើបានយូរ?

៥. នេះអាចរួមបញ្ចូលទាំងការសាកល្បងនៅក្នុងភាពពិត។តើអ្នកអាចទិញឬក៏សាកល្បងផលិតផលបានដែរឬទេ?

៦. រៀបចំការធ្វើបទបង្ហាញមួយដែលមានរយៈពេល៥នាទី ៖

  ក. រូបភាពមួយ នៃផលិតផលជាច្រើន រូបថត គំនូរ ឬក៏បង្ហាញពួកគេនូវលក្ខណៈពិតៗ

  ខ. ដំណាក់កាលបន្តបន្ទាប់នៃការអង្កេត និងអ្វីដែលអ្នកបានធ្វើនៅក្នុងផលិតផល ទាំងនេះ

  គ. បង្ហាញលទ្ធផលនៅលើតារាង ឬដ្យាក្រាម

  ឃ. ការសន្និដ្ឋានចុងក្រោយចំពោះក្រុមដទៃទៀត ដោយផ្តល់ជាដំបូន្មាន និងពីរបៀប ដែលយើងគួរតែប្រើប្រាស់ផលិតផលទាំងអស់នេះ។

# មេរៀនទី ៩: ការផ្សព្វផ្សាយ

🕑 រយៈពេលបង្រៀន: ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ក្រដាសតូចៗពណ៌ស ទំហំA5
- ស្កុត
- ម៉ាស៊ីនថតរូប ដើម្បីថតរូបសម្រាប់កាសែត ឬដើម្បីធ្វើការបង្ហាញនៅចុងបញ្ចប់នៃ ឯកសារនេះ

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- ចែករំលែកនូវបទបង្ហាញរបស់ពួកគេចំពោះក្រុមដទៃទៀត
- សហការក្នុងក្រុមដើម្បីដោះស្រាយសំណួរ

**សេចក្ដីផ្ដើម:** នរណាជាអ្នកដឹកនាំ 🕑 ២០ នាទី

👄 យើងនឹងលេងល្បែងមួយដែលមានឈ្មោះថា "ល្បែងបាល់ក្រដាស"។ ខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នា គិតពីចំណុចសំខាន់ៗដែលយើងបានរៀននៅក្នុង ៨មេរៀនខាងមុខ។ បង្កើតទម្រង់សំណួរ ដែលត្រូវសួរអំពីចំណុចសំខាន់ៗទាំងនេះ។ ឧទាហរណ៍ៈ តើជាងកាត់សក់ប្រើសម្ភារៈអ្វីសម្រាប់តម្រឹមសក់? (កន្ត្រៃគុងដឹ)។ អ្នកទាំងអស់គ្នាអាចសរសេរសំណួរដោយមិនមានចម្លើយនៅលើក្រដាស ដែលខ្ញុំនឹងផ្ដល់ឱ្យ។

✋ ផ្ដល់ឱ្យសិស្សនូវក្រដាសពណ៌ស ដើម្បីឱ្យពួកគេសរសេរនូវសំណួរ។

👄 ប្រសិនបើអ្នកទាំងអស់គ្នាបានសរសេរសំណួររួចរាល់ហើយ អ្នកអាចច្របាច់ក្រដាសនោះឱ្យ មូលដូចបាល់។ ឱ្យសិស្សចំនួន ៤នាក់ ជ្រើសរើសយក "បាល់" របស់ពួកគេ ហើយចាប់ផ្ដើមគ្រវែងបាល់នោះទៅកាន់សិស្សដទៃទៀត។ នៅចន្លោះពេលនោះផងដែរ ខ្ញុំនឹងរាប់ដល់១០។ នៅពេលដែលខ្ញុំនិយាយថា១០ សិស្សដែលកំពុងកាន់បាល់នោះអាចបើកបាល់នោះមើលបាន ហើយអាននូវសំណួរនោះ។ អ្នកទាំងអស់គ្នាអាចព្យាយាមឆ្លើយសំណួរ ប៉ុន្តែ ប្រសិនបើអ្នកមិនអាចឆ្លើយបាន បន្ទាប់មកទៀតអ្នកដទៃអាចជួយឆ្លើយ។

✋ លេងល្បែងនេះរហូតដល់សំណួរទាំងអស់ត្រូវបានសួរ និងឆ្លើយ។

## សកម្មភាពសំខាន់។

🕑 ៦៥ នាទី

ថ្ងៃនេះយើងនឹងទស្សនាការតាំងពិព័រណ៍ដ៏ល្អ។ អ្នកជំនាញមកពីទូទាំងប្រទេសកម្ពុជា បានមកកាន់ថ្នាក់រៀននេះ ដើម្បីបង្ហាញអ្នកនូវផលិតផលសម្រាប់ប្រើលើសក់ ។ ពួកគេក៏ នឹងធ្វើការប្រៀបធៀបនូវផលិតផល ២ ព្រមទាំងផ្តល់ឱ្យអ្នកនូវដំបូន្មានមួយចំនួនផងដែរ។ សម្រាប់ព្រឹត្តិការណ៍នោះផងដែរ យើងនឹងបែងចែកសិស្សក្នុងថ្នាក់ជា ២ក្រុមគឺ សិស្សពាក់កណ្តាលធ្វើបទបង្ហាញរបស់ពួកគេ ទៅកាន់សិស្សពាក់កណ្តាលទៀតដែលជាអ្នកស្តាប់។ សម្រាប់ក្រុមទាំងអស់មានរយៈពេល ៥នាទី ដើម្បីជ្រើសរើសកន្លែងមួយ ដែលពួកគេចង់ធ្វើបទបង្ហាញ ហើយត្រូវដាក់សម្ភារៈទាំងអស់ឱ្យបានរួចរាល់ ដើម្បីឱ្យសាធារណជនមើល។ សិស្សដទៃទៀត នឹងធ្វើតាមនៅពេលក្រោយ ប៉ុន្តែជាដំបូងពួកគេទាំងនោះ នឹងត្រូវបានអញ្ជើញឱ្យមើលក្រុមដទៃជាមុនសិន ។ អ្នកនឹងមានឱកាសដើម្បីមើលដៃគូចំនួន ៦គូ ធ្វើបទបង្ហាញ។ រៀងរាល់ ៥ នាទីម្តង ខ្ញុំនឹងស្រែកប្រាប់ពួកគេ ដល់ពេលដែលត្រូវប្តូរវេណម្តង។ អ្នកត្រូវធ្វើការ ជ្រើសរើសគូផ្សេងមួយទៀត។ អ្នកមិន អាចទៅមើលគូ ដែលបានបង្ហាញរួចហើយ ជាសាធារណៈបានឡើយ។

រង់ចាំរយៈពេល៥នាទី ហើយធ្វើការពិនិត្យមើលថា តើសិស្សទាំងអស់បានត្រៀមរួចរាល់ហើយឬនៅសម្រាប់ការធ្វើបទបង្ហាញរបស់ពួកគេ។ ប្រាប់ទស្សនិកជនថា ពួកគេត្រូវតែយកចិត្តទុកដាក់ស្តាប់ឱ្យបានល្អ ដោយសារតែអ្នកទាំងអស់គ្នានឹងត្រូវសួរសំណួរជាច្រើនអំពីការធ្វើបទបង្ហាញរបស់ ពួកគេ។

បន្ទាប់ពីនោះមក ចូរដើរជុំវិញ ហើយធ្វើការបំពេញនៅក្នុង*ក្រដាសវាយតម្លៃការសិក្សារបស់ សិស្ស។*

បន្ទាប់ពីរយៈពេល ៣០ នាទី ៖

វាដល់ពេលដែលត្រូវប្តូរវេណគ្នាម្តងហើយ ព្រោះពេលនេះទស្សនិកជននឹងក្លាយទៅជាអ្នកធ្វើ បទបង្ហាញ ហើយចំណែកឯសិស្ស ដែលបានធ្វើបទបង្ហាញរួច គឺធ្វើជាទស្សនិកជនម្តង។ អ្នកអាចជ្រើសរើស ការធ្វើបទបង្ហាញមួយណាក៏បាន ដែលអ្នកចង់។

ធ្វើបទបង្ហាញមួយជុំទៀត ដែលនឹងត្រូវចំណាយពេល ៣០ នាទី។

## បញ្ចប់មេរៀន

🕑 ៥ នាទី

អរគុណអ្នកទាំងអស់គ្នាខ្លាំងណាស់ សម្រាប់ការធ្វើបទបង្ហាញដ៏ល្អ និងទូលំទូលាយ។ ចំពោះ កិច្ចការផ្ទះរបស់អ្នក គឺនឹងត្រូវសរសេរពីមតិរិះគន់ស្តីអំពីការធ្វើបទបង្ហាញទាំងនេះ។

ការសរសេរពណ៌នាខ្លីមួយ ស្តីអំពីខ្លឹមសារដែលអ្នកបានរៀន ពីការធ្វើបទបង្ហាញខុសៗគ្នាជាច្រើន និងដំបូន្មានមួយចំនួនសម្រាប់អ្នកធ្វើបទបង្ហាញទាំងអស់នោះ។

### សេចក្តីណែនាំគ្រូ

ល្បែង "បាល់ក្រដាស" គឺត្រូវបានបង្ហាញនៅលើគេហទំព័រ www.ibec.worlded.org។ វាក៏បានធ្វើការពណ៌នានៅក្នុងកូនសៀវភៅតូចៗដែលត្រូវបានចែកជូននៅតាមសាលាមួយចំនួន។ធ្វើការពិនិត្យមើលប្រសិនបើអ្នកអាចទទួលបានសៀវភៅនោះមួយក្បាល ប្រសិនបើ អ្នកមិនដឹងច្បាស់អំពីល្បែងនោះ។

# មេរៀនទី ១០: ការវាយតម្លៃ

🕑 រយៈពេលបង្រៀនៈ ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ក្រដាសតូចមួយ ដែលមានពាក្យទាក់ទងនឹងការកាត់សក់
- ទម្រង់តេស្ត

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- វាយតម្លៃទៅលើបំណិនកាត់សក់

**សេចក្ដីផ្ដើមៈ** តើខ្ញុំជាអ្វី 🕑 ២០ នាទី

នៅពេលដែលសិស្សទាំងអស់ ចូលមកក្នុងថ្នាក់រៀន អ្នកបិទក្រដាសតូចមួយ នៅលើខ្នងពួកគេ ដោយប្រើស្កុត ហើយនៅលើក្រដាសនោះ មានពាក្យមួយក្នុងចំណោមពាក្យទាំងនេះ ៖ កន្ត្រៃ សក់ កន្ត្រៃតុងដឺ សាប៊ូ ប្រេងអប់សក់ ក្រាស ជក់ កញ្ចក់ កាំបិតកោរ កៅអី ម្សៅ ជាងកាត់សក់ កន្ត្រៃសាប់ ម្សៅសម្រាប់កក់សក់ស្បែកក្បាល ឧបករណ៍ធ្វើឱ្យសក់ស្ងួត ជក់ជាគ្រឿងសម្រាប់តុបតែង ឧបករណ៍សម្រាប់ពន្លាសក់ ក្រែមសម្រាប់កោរ ចាហួយលាបសក់ ក្រមួនឧបករណ៍ សម្រាប់ធ្វើសក់ឱ្យរួញ។

អ្នកទាំងអស់គ្នា គឺជារបស់អ្វីមួយដែលទាក់ទងទៅនឹងការអ៊ុតសក់ ឬកាត់សក់។ ឥឡូវនេះអ្នកត្រូវស្វែងរកថា អ្នកជាអ្វី។ អ្នកទាំងអស់គ្នាក៏អាចសួរសិស្សដទៃទៀតនូវសំណួរ មួយផងដែរ ដោយសំណួរមួយសម្រាប់សិស្សគ្រប់គ្នា។ ពួកគេគ្រាន់តែអាចឆ្លើយថា "បាទ/ចាស" "ទេ" ឬ "ប្រហែល"។ ដូច្នេះដំបូងអ្នកចាំបាច់ត្រូវស្វែងយល់ពីខ្លួនអ្នកគឺ ជារបស់អ្វីមួយ ឬឧបករណ៍មួយ ឬអ្វីមួយផ្សេងទៀត។ នៅពេលដែលអ្នកដឹងថា ខ្លួនអ្នកគឺជាអ្វីមួយ អ្នកអាចឈរនៅខាងមុខក្ដារខៀន។

១.គ្រូដើរជុំវិញ ដោយឆ្លងកាត់ថ្នាក់រៀន ហើយសួរសំណួរមួយទៅកាន់សិស្សទាំងអស់គ្នា។ ការពិតនៅពេលដែលអ្នកសួរសំណួរមួយ អ្នកក៏ត្រូវតែឆ្លើយសំណួរនោះសម្រាប់សិស្សទាំងអស់នោះផងដែរ។

*សំណាងល្អ!* សិស្សទាំងអស់

២. ប្រសិនពួកគេគិតថា ការធ្វើបែបនោះមានលក្ខណៈពិបាក អ្នកក៏អាចជួយពួកគេ ដោយឱ្យដំបូន្មាន មួយចំនួនផងដែរ។

៣. ឧទាហរណ៍ ៖ "តើខ្ញុំអាចប្រើ ប្រាស់បានទេ?" "តើខ្ញុំត្រូវបានប្រើសម្រាប់សក់?" "តើខ្ញុំមានមាឌ ធំមួយ?" "តើអ្នករាល់គ្នា មានខ្ញុំនៅផ្ទះដែរទេ?"

៤. បន្ទាប់ពីសិស្សទាំងអស់គ្នាដឹងថា ខ្លួនពួកគេជាអ្វី អ្នកអាចឱ្យពួកគេពិនិត្យមើលប្រសិនបើ ពួកគេឆ្លើយបានត្រឹមត្រូវ។

## សកម្មភាពសំខាន់។

៦៥ នាទី

នៅចុងបញ្ចប់នៃឯកសារ ស្តីអំពីការកាត់សក់នេះ យើងនឹងផ្តល់ឱ្យអ្នកទាំងអស់គ្នានូវការ ប្រឡងមួយដើម្បី បង្ហាញថា តើអ្នកទាំងអស់គ្នាសិក្សាអំពីចំណុចទាំងនោះ បានប៉ុន្មាន ហើយខ្ញុំនឹងចែកវាទៅឱ្យអ្នកទាំងអស់គ្នា។ អ្នកនឹងមានរយៈពេល៣០នាទី ដើម្បីបំពេញចំណុចទាំងនោះ។

ឱ្យក្រដាសវាយតម្លៃទៅសិស្សទាំងអស់ ហើយឱ្យពួកគេធ្វើបុគ្គល។

## បញ្ចប់មេរៀន

៥ នាទី

លោកគ្រូ/អ្នកគ្រូ បង្ហាញចម្លើយដល់សិស្ស ដើម្បីឱ្យសិស្សបានដឹង នូវសំណួរដែលពួកគេបានបំពេញ។

អរគុណអ្នកទាំងអស់គ្នាខ្លាំងណាស់ សម្រាប់ការធ្វើបទបង្ហាញដ៏ល្អ និងទូលំទូលាយ។ ចំពោះ កិច្ចការផ្ទះរបស់អ្នក គឺនឹងត្រូវសរសេរពីមតិរិះគន់ស្តីអំពីការធ្វើបទបង្ហាញទាំងនេះ។

## សេចក្តីណែនាំគ្រូ

គេហទំព័រ www.ibec.worlded.org។ វាក៏បានធ្វើការពណ៌នានៅក្នុងកូនសៀវភៅតូចៗ ដែលត្រូវបានចែកជូននៅតាមសាលាមួយចំនួនដែរ។

# ទម្រង់វាយតម្លៃ

ឈ្មោះ.......................................ភេទ.............ថ្នាក់ទី...............សាលា.........................................

ស្រុក.......................................ខេត្ត...............................................

**វិញ្ញាសាសរសេរ វាយតម្លៃសិស្ស ស្តីអំពីការកាត់សក់**

១. ហេតុអ្វីបានជាវាមានសារៈសំខាន់សម្រាប់ជាងកាត់សក់ ក្នុងការនិយាយទៅកាន់ភ្ញៀវ? បង្ហាញនូវហេតុផលយ៉ាងហោចណាស់ឱ្យបាន២។



២. តើឧបករណ៍មួយណាដែលមិនមាននៅក្នុងបញ្ជី?

*កន្ត្រៃ កំណាត់ កាំបិតកោរ កន្ត្រៃគុងជី កាំបិត ដក់*

៣. ត្រូវ ឬ ខុស?

| | ត្រូវ | ខុស |
|---|---|---|
| វា គឺជាការសំខាន់ក្នុងការធ្វើឱ្យហាងកាត់សក់របស់អ្នកស្អាត | | |
| ម៉ូតសក់មួយតែងតែនិយាយពីអ្វីមួយ អំពីបុគ្គលិកលក្ខណៈ | | |
| អ្នកត្រូវតែសម្អាតសក់របស់អ្នកនៅរៀងរាល់២ថ្ងៃម្តង | | |
| កន្ត្រៃគុងជី ត្រូវបានប្រើសម្រាប់កោរពុកមាត់ | | |
| ម្សៅដែលដាក់នៅលើសក់ ជួយជាងកាត់សក់ឱ្យមើលឃើញផ្នែកមួយណាដែលបានកាត់រួច | | |

៤. តើអ្នកអាចពណ៌នាពីជំហានទាំង៤ ដើម្បីរៀបចំសម្រាប់កាត់សក់នរណាម្នាក់បានដែរទេ?

៥. តើអ្នកត្រូវធ្វើដូចម្តេច?

*អ្នកកំពុងតែឈរនៅក្នុងហាង ហើយចង់ទិញសាប៊ូសម្រាប់កក់សក់របស់អ្នក។ អ្នកលក់ប្រាប់អ្នកថាដោយសារតែអ្នកមានសក់បែបអាស៊ី អ្នកក៏នឹងត្រូវការប្រេងអប់សក់ផងដែរ។ វានឹងធ្វើឱ្យសក់ របស់អ្នក មើល ទៅស្អាត "នាងនិយាយ"។ ជាអកុសល ប្រេងអប់សក់នោះមានតម្លៃ២ដុល្លារ។ តើអ្នក ត្រូវធ្វើដូចម្តេច?*

៦. តើម៉ូតសក់មួយណា ដែលអ្នកចង់បាន? ចូរពន្យល់ពីមូលហេតុ។

៧. តើអ្វីខ្លះដែលជាសារៈសំខាន់ទាំង៣ នៃការសម្អាតសក់របស់អ្នក ដោយប្រើម្សៅកក់សក់ ជំនួស សាប៊ូ?

៨. ចូរបែងចែកពាក្យជាច្រើនខាងក្រោមនេះ ទៅតាមប្រភេទនីមួយៗ។ អ្នកត្រូវធ្វើការសម្រេចចិត្តថា តើវាចូលទៅក្នុងប្រភេទមួយណា ប៉ុន្តែត្រូវតែច្បាស់លាស់។

*សាប៊ូម៉ាទីស - ឧបករណ៍សម្រាប់ពត់គ្របកន្ទែក - ប្រេងអប់សក់ ឡូរ៉េល - ក្រែមសម្រាប់កោរ - សក់ ពណ៌បៃតង - ឧបករណ៍ពន្លាសក់ - ម្សៅសម្រាប់កក់សក់ - ចាហួយលាបសក់ អាឌីដាស - សក់ពាក់ - សក់ហាយឡាយ-ដុំសក់ -កាំបិតកោរ - ខ្មៅដៃសម្រាប់គូរចញ្ចើម - ក្រាស។*

៩. ចូរប្រាប់ឈ្មោះសម្ភារៈរបស់ជាងកាត់សក់ខុសៗគ្នាខាងក្រោមនេះ ហើយពណ៌នាពីអ្វី ដែលអ្នកអាចធ្វើជាមួយនឹងវា។




១០. ចូរបង្ហាញនូវវត្ថុចំនួន២ ដែលអ្នកបានរៀននៅអំឡុងពេលសិក្សាប្រធានបទនេះ និងធ្វើការ ពណ៌នា ពីវិធីដែលអ្នកប្រើប្រាស់វានៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក។

| |
|---|
| ពិន្ទុសរុប :<br>និទ្ទេស : |

**ចម្លើយវិញ្ញាសាសរសេរ វាយតម្លៃសិស្ស ស្ដីអំពីការកាត់សក់**

១. អាចមានចម្លើយពីរបីចំពោះសំណួរនេះ។ វា គឺសំខាន់ណាស់សម្រាប់ជាងកាត់សក់ម្នាក់ ក្នុងការនិយាយជាមួយនឹងភ្ញៀវរបស់គាត់ដោយសារតែ ៖

a. គាត់អាចធ្វើឱ្យភ្ញៀវមានអារម្មណ៍កក់ក្ដៅ ដូច្នេះពួកគេនឹងមកម្ដងទៀត។
b. ពួកគេអាចយល់ស្របគ្នាទៅលើតម្លៃ។
c. គាត់ចាំបាច់ត្រូវដឹងថា តើម៉ូតសក់អ្វីដែលពួកចង់បាន។
d. គាត់អាចឱ្យដំបូន្មានពួកគេអំពីម៉ូតសក់។
e. ពិភាក្សាគ្នាពីពេលវេលា ដែលត្រូវការសម្រាប់ការកាត់សក់ ឬដើម្បីរៀបតារាងពេលវេលាសាជាថ្មី នៅពេលដែលវារវល់។

ឆ្លើយត្រូវ២ = ២ពិន្ទុ
ឆ្លើយត្រូវ១ = ១ពិន្ទុ

២. កាំបិតមិនមាននៅក្នុងបញ្ជីទេ។
ឆ្លើយត្រូវ = ១ពិន្ទុ

៣.

| | ត្រូវ | ខុស |
|---|---|---|
| វា គឺសំខាន់ក្នុងការធ្វើឱ្យហាងកាត់សក់របស់អ្នកស្អាត | X | |
| ម៉ូតសក់មួយតែងតែនិយាយអ្វីមួយ អំពីបុគ្គលិកលក្ខណៈ | | X |
| អ្នកត្រូវតែសម្អាតសក់របស់អ្នកនៅរៀងរាល់២ថ្ងៃម្ដង | | X |
| កន្ត្រៃកុងជី ត្រូវបានប្រើសម្រាប់កោរពុកមាត់ | | X |
| ម្សៅដែលដាក់នៅលើសក់ ជួយជាងកាត់សក់ឱ្យមើលឃើញផ្នែកមួយណាដែលបានកាត់រួច | X | |

ឆ្លើយត្រូវជាង៣ = ២ពិន្ទុ
ឆ្លើយត្រូវ២ឬ៣ = ១ពិន្ទុ
ឆ្លើយត្រូវតិចជាង៣ = ០ពិន្ទុ

៤. ជំហានទាំង៤រួមមានដូចជា៖

- ស្វាគមន៍អតិថិជន ហើយសួរថា តើនាង/គាត់ចង់បានសក់ម៉ូតដូចម្ដេច?
- រុំកំណាត់ជុំវិញករបស់ភ្ញៀវ
- សិតសក់ ដើម្បីឱ្យវារាបស្មើ
- ប្រើម្សៅលាបជុំវិញក្បាល

មាននូវប្រភេទរបស់ខុសៗគ្នាមួយចំនួននៅក្នុងជំហានទាំងនេះ ប៉ុន្តែពួកគេគួរតែរួមបញ្ចូលការពណ៌នាមួយនៃជំហានរបស់វាផ្ទាល់ដែរ។

ឆ្លើយត្រូវជំហានទាំង៤ = ២ពិន្ទុ

ឆ្លើយត្រូវតែ៣ជំហាន = ១ពិន្ទុ

៥. ដោយផ្អែកលើការយល់ហេតុផលរបស់ចម្លើយនេះ ដូច្នេះវាអាស្រ័យទៅលើគ្រូដើម្បីធ្វើការសម្រេច ចិត្ត។

ឆ្លើយបានល្អ ដោយមានការពន្យល់សមហេតុផល = ១ពិន្ទុ

៦. ចំពោះចម្លើយនេះ គឺផ្អែកទៅលើការពន្យល់របស់សិស្ស ដែលផ្ដល់ឱ្យចំពោះម៉ូតរបស់ពួកគេ។ ដោយគ្រាន់ តែឆ្លើយថា "ដោយសារតែខ្ញុំចូលចិត្តវា" គឺមិនហ្មត់ចត់គ្រប់គ្រាន់នោះទេ។ ការប្រាប់ហេតុផល គឺគួរនិយាយអ្វីមួយអំពីហេតុផលជាមូលដ្ឋានរបស់ពួកគេ។

ឆ្លើយបានល្អ = ១ពិន្ទុ

៧. គុណប្រយោជន៍គឺ ៖

- វាមានតម្លៃថោកជាង
- វាមិនចាំបាច់កំចាត់ជាតិប្រេង ដែលសំខាន់ពីស្បែកក្បាលរបស់អ្នក
- អ្នកមិនចាំបាច់ប្រើទឹក

ឆ្លើយត្រូវ ៣ = ១ពិន្ទុ

៨. ដោយអាស្រ័យទៅលើប្រភេទជាច្រើន ដែលសិស្សបានបង្កើតឡើង ការធ្វើបែបនេះ អាចមើល ដូចខាងក្រោម ៖

| ដើម្បីសម្អាត | គ្រឿងតុបតែង | សក់ក្លែងក្លាយ | ជាងកាត់សក់ |
|---|---|---|---|
| សាប៊ូម៉ាទីស | ឧបករណ៍សម្រាប់ពត់ | ឧបករណ៍ពន្លាសក់ | ក្រែមសម្រាប់ |
| ប្រេងអប់សក់ ឡូរ៉េល | គ្របកភ្នែក | សក់ពណ៌បៃតង | កោរ |
| ចាហួយលាបសក់ អាឌីដាស | ខ្មៅដៃសម្រាប់គូរចញ្ចើម | ជុំសក់ | កាំបិតកោរ |
| ម្សៅសម្រាប់កក់សក់ | | សក់ពាក់ | ក្រាស |

ចាត់ទៅតាមប្រភេទឱ្យបានច្បាស់ និងបែងចែកត្រឹមត្រូវ = ២ពិន្ទុ

ចាត់ទៅតាមប្រភេទឱ្យបានច្បាស់ ប៉ុន្តែបែងចែកមិនត្រឹមត្រូវ = ១ពិន្ទុ

៩. A= កន្ត្រៃកុងដឺ

B= ដបបាញ់ទឹក( ប្រេង ឬទឹក)

C= កំណាត់សំពត់

ឆ្លើយត្រូវទាំង៣ = ២ពិន្ទុ

ឆ្លើយត្រូវ២ = ១ពិន្ទុ



១០. អាស្រ័យទៅលើការពន្យល់ពីសិស្ស ដែលចម្លើយអាចត្រូវបានកត់ចំណាំដោយគ្រូ។

ឆ្លើយបានសមហេតុផល = ១ពិន្ទុ

**កម្រិតនៃការផ្តល់ពិន្ទុ-ពិន្ទុនៅក្នុងការធ្វើតេស្តនេះ គឺទាក់ទងទៅនឹងពិន្ទុទូទៅ**

| %ឆ្លើយបានត្រឹមត្រូវ | ពិន្ទុ | និទ្ទេស |
|---|---|---|
| ៦៦%ទៅ១០០%ល្អ | ច្រើនជាង៩ពិន្ទុ | ល្អ |
| ៥១%ទៅ៦៥%ល្អ | ៨ទៅ៩ពិន្ទុ | បង្គួរ |
| ក្រោម៥០%ល្អ | តិចជាង៨ពិន្ទុ | ខ្សោយ |

## ឧបសម្ព័ន្ធ ១.១ : គំរូប័ណ្ណវាយតម្លៃ (សម្រាប់គ្រូ)

# ប័ណ្ណវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ

ឈ្មោះសិស្ស ........................ សាលា..................... . ខេត្ត.............. ស្រុក................. ថ្នាក់ទី ........ ប្រធានបទ...............

| | ចំណុចត្រូវដាក់ពិន្ទុ | ពិន្ទុ (១-១៥) | និទ្ទេស |
|---|---|---|---|
| **កិច្ចការទី ១: តេស្តចំណេះដឹង (សំណួរសរសេរ)** | | | |
| សំណួរសរសេរមានពិន្ទុសរុប ១៥ ពិន្ទុ | បើពិន្ទុ 0 ដល់ ៧=ខ្សោយ/ បើ ៨ ដល់ ១០=មធ្យម / បើ ១១ ដល់ ១៥=ល្អ) | | |
| | **សង្កេតឥរិយាបថសិស្ស** | ពិន្ទុ (១-៥) | និទ្ទេស |
| ១ | **ការប្រាស្រ័យទាក់ទង និងការសហការ :** សកម្មភាពពិភាក្សាជាមួយសមាជិកទាំងអស់ក្នុងក្រុម និងធ្វើការបានប្រសើរ ជាមួយក្រុម ។ សិស្សស្តាប់គ្នាទៅវិញទៅមក និងផ្តល់យោបល់គ្នាទៅវិញទៅមក ។ | | |
| ២ | **ការវិភាគល្អិតល្អន់ និងការដោះស្រាយបញ្ហា :** ផ្តល់ចម្លើយដោយមានហេតុផល និងអំណះអំណាងច្បាស់លាស់ និងអាចកំណត់ដំណោះស្រាយចំពោះបញ្ហាងាយៗដែលជួបប្រទះ ។ | | |
| ៣ | **ការធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង :** មិនមានការបារម្ភច្រើន ក្នុងការធ្វើសេចក្តីសំរេចចិត្ត និងដឹងច្បាស់ថាខ្លួនគេកំពុងនិយាយឬធ្វើអ្វីមួយ ។ | | |
| ៤ | **ទំនុកចិត្តលើខ្លួនឯង :** កំឡុងពេលធ្វើបទបង្ហាញនិងពិភាក្សាក្រុម សិស្សមានទំនុកចិត្តក្នុងការនិយាយ និងចូលរួមក្នុងក្រុម | | |
| ៥ | **ការលើកទឹកចិត្ត និងការយល់ចិត្ត:** សិស្សចង់បន្តរៀនសូត្របន្ថែមពីប្រធានបទនេះ ហើយយល់ច្បាស់ខ្លឹមសារក្នុង ប្រធានបទ និងការអនុវត្តផ្ទាល់ ។ | | |
| ៦ | **ចរិត : សិស្ស**មានចិត្តអំណត់និងអារម្មណ៍ល្អនៅក្នុងការសិក្សា ។ | | |
| ៧ | **ការបង្កើតថ្មី :** សិស្សបង្ហាញនូវភាពច្នៃប្រឌិតក្នុងការរៀបចំការធ្វើបទបង្ហាញផលិតផល នៅកំឡុងពេលសិក្សា ដោយបង្ហាញចេញនូវគំនិតជាច្រើន ។ | | |
| | **សរុបសង្កេតឥរិយាបថសិស្ស** | | |
| សង្កេតឥរិយាបថសិស្សមានពិន្ទុសរុប ៣៥ ពិន្ទុ ( បើពិន្ទុ 0 ដល់ ១៧ =ខ្សោយ/ បើ ១៨ ដល់ ២៣=មធ្យម / បើ ២៤ ដល់ ៣៥=ល្អ) | | | |
| ពិន្ទុសរុបសំណួរសរសេរ និងសង្កេតឥរិយាបថសិស្ស ( បើពិន្ទុ 0 ដល់ ២៤=ខ្សោយ/ បើ ២៥ ដល់ ៣៣=មធ្យម / បើ ៣៤ ដល់ ៥០=ល្អ) | | | |

ថ្ងៃទី .......... ខែ ........... ឆ្នាំ ..........

ហត្ថលេខា និងឈ្មោះគ្រូ

## ឧបសម្ព័ន្ធ ១.២ : តារាងបូកសរុបលទ្ធផលវាយតម្លៃការសិក្សារបស់សិស្សប្រចាំថ្នាក់

ខេត្ត ........................... ស្រុក .........................សាលា .............................. ថ្នាក់ទី ........... ប្រធានបទ ....................

| ល.រ | ឈ្មោះសិស្ស | សំណួរសរសេរ | | គរិយាបថ | | សរុប | |
|---|---|---|---|---|---|---|---|
| | | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |
| ៨ | | | | | | | |
| ៩ | | | | | | | |
| ១០ | | | | | | | |
| ១១ | | | | | | | |
| ១២ | | | | | | | |
| ១៣ | | | | | | | |
| ១៤ | | | | | | | |
| ១៥ | | | | | | | |
| ១៦ | | | | | | | |
| ១៧ | | | | | | | |
| ១៨ | | | | | | | |
| ១៩ | | | | | | | |
| ២០ | | | | | | | |
| ២១ | | | | | | | |
| ២២ | | | | | | | |
| ២៣ | | | | | | | |
| ២៤ | | | | | | | |
| ២៥ | | | | | | | |
| ២៦ | | | | | | | |

បានឃើញ និងឯកភាព　　　　　　　　　　ថ្ងៃទី ........... ខែ ............. ឆ្នាំ ...........

នាយកសាលា　　　　　　　　　　ហត្ថលេខា និងឈ្មោះគ្រូបង្រៀន

<table>
<tr><td colspan="4">ការអង្កេតថ្នាក់រៀន</td><td colspan="2">ការវាយតម្លៃគ្រូបំណិនជីវិត</td></tr>
<tr><td colspan="4">សាលារៀន</td><td>គ្រូ</td><td>អ្នកសង្កេត</td></tr>
<tr><td colspan="4"></td><td></td><td></td></tr>
<tr><td>កាលបរិច្ឆេទ</td><td>ការចាប់ផ្ដើមមេរៀន</td><td>ការបញ្ចប់មេរៀន</td><td>ថ្នាក់</td><td>ចំនួនសិស្សដែលបានចុះឈ្មោះ/មានវត្តមាន</td><td>ប្រធានបទបំណិនជីវិត:</td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td colspan="6">តើមេរៀនបង្ហាញពីអ្វី?</td></tr>
<tr><td colspan="6"></td></tr>
</table>

<table>
<tr><td>លក្ខណៈវិនិច្ឆ័យ – ការរៀបចំ – តើបន្ទប់រៀន..</td><td>ពិន្ទុ</td><td>កំណត់សម្គាល់យោងតាមភស្តុតាង</td></tr>
<tr><td>មានសណ្ដាប់ធ្នាប់ ហើយ ត្រៀមសម្ភារៈរួចជាស្រេចសម្រាប់ប្រើប្រាស់ក្នុងមេរៀននេះ?</td><td>1-2-3-4-5</td><td></td></tr>
<tr><td>បង្ហាញសិស្សនូវសម្ភារៈដែលបានធ្វើកាលពីមេរៀនមុន</td><td>1-2-3-4-5</td><td></td></tr>
<tr><td>លក្ខណៈវិនិច្ឆ័យ - ការសិក្សា - តើសិស្ស...</td><td>ពិន្ទុ</td><td>កំណត់សម្គាល់យោងតាមភស្តុតាង</td></tr>
<tr><td>មានចំណាប់អារម្មណ៍ និងចូលរួមក្នុងការងាររបស់ពួកគេដែរឬទេ?</td><td>1-2-3-4-5</td><td></td></tr>
<tr><td>ធ្វើការក្នុងក្រុមខុសៗគ្នាក្នុងកំឡុងពេលបង្រៀនដោយមានតួនាទីក្រុមច្បាស់លាស់</td><td>1-2-3-4-5</td><td></td></tr>
<tr><td>រីករាយជាមួយមេរៀនដែលគ្រូបង្រៀន</td><td>1-2-3-4-5</td><td></td></tr>
<tr><td>បង្ហាញចំណេះដឹង ឬបំណិនពីមេរៀនមុន</td><td>1-2-3-4-5</td><td></td></tr>
<tr><td>លក្ខណៈវិនិច្ឆ័យ – ការបង្រៀន – តើគ្រូ..</td><td>ពិន្ទុ</td><td>កំណត់សម្គាល់យោងតាមភស្តុតាង</td></tr>
<tr><td>អនុវត្តតាមកិច្ចតែងការបង្រៀនដែលមានឬទេ?</td><td>1-2-3-4-5</td><td>សូមបញ្ជាក់ធាតុណាមួយដែលត្រូវបានប្រើ</td></tr>
<tr><td>ប្រើប្រាស់ធនធានសហគមន៍ក្នុងការបង្រៀនមេរៀននេះ ឬប្រើប្រាស់សហគមន៍ទាំងស្រុង?</td><td>1-2-3-4-5</td><td></td></tr>
</table>

| | | |
|---|---|---|
| ប្រើប្រាស់វិធីសាស្ត្របង្រៀនបែបអន្តរកម្ម/សកម្ម ឧ.ផែនទីគំនិត, ករណីសិក្សា, ការសម្តែងតួ, ល្បែងកំសាន្ត... | 1-2-3-4-5 | |
| ប្រើប្រាស់ប្រភេទសំណួរផ្សេងៗ | 1-2-3-4-5 | |
| ប្រើប្រាស់ធនធានបង្កើតឡើងដោយខ្លួនឯង ឬឯកសារបន្ថែមដើម្បីពន្យល់មេរៀន | 1-2-3-4-5 | |
| ចាប់ផ្តើមតាមពេលកំណត់ និងប្រើប្រាស់ពេលវេលាយ៉ាងមានប្រសិទ្ធភាព | 1-2-3-4-5 | |
| ផ្តល់មតិយោបល់វិជ្ជមានដើម្បីជំរុញការសិក្សា និងបង្កើនទំនុកចិត្តដល់សិស្ស | 1-2-3-4-5 | |
| ជួយសិស្សជាលក្ខណៈបុគ្គលចំពោះសិស្សណាដែលមានការលំបាក | 1-2-3-4-5 | |
| កត់ត្រាការវិវត្តនៃអត្តចរិតសិស្សក្នុងតារាងវាយតម្លៃការសិក្សារបស់សិស្ស? | 1-2-3-4-5 | |

បន្ទាប់ពីផ្នែកនេះ ចូរប្រើប្រាស់កំណត់ត្រារបស់អ្នកដើម្បីពិភាក្សាជាមួយគ្រូ។ **សុំឱ្យគ្រូកំណត់ចំណុចល្អរបស់មេរៀន** ហើយស្នើសុំការផ្លាស់ប្តូរ ឬការកែលម្អ។ ធ្វើការជាមួយគ្រូដើម្បីកំណត់ភាពខ្លាំង។ ធ្វើការផ្តល់គំនិតចំពោះការកែលម្អ។ ការសង្កេតត្រូវបានបញ្ចប់ ដោយធ្វើការសម្ភាសន៍។

| ចំណុចខ្លាំង | គំនិតសម្រាប់កែលម្អ |
|---|---|
| | |

ហត្ថលេខា និងឈ្មោះរបស់អ្នកវាយតម្លៃ ......................

ហត្ថលេខា និងឈ្មោះរបស់គ្រូ ...................................


សម្ភារៈរបស់ជាងកាត់សក់
សម្ភារៈជាងកាត់សក់
កន្ត្រៃរុញដីប្រើអគ្គិសនី
កន្ត្រៃច្រិប
កន្ត្រៃសាប់
កន្ត្រៃរុញដី
ដងឡាម
ផ្លែឡាម
ក្រាសធំ
ក្រាសតូច
ថ្នាំកោរពុកមាត់
ដបបាញ់ទឹក
ជក់បោសសក់
កាំបិតកោរ
កំប៉ុងម្សៅ
ប្រដាប់ចងសក់
ថ្នាំលាបសក់
សាប៊ូម្សៅ
សម្ភារៈជាងកាត់សក់
ដង្កៀប
ដង្កៀបសក់
សាប៊ូក្រែម
USAID

ក្រសួងកិច្ចការនារី

DEUTSCHE ZUSAMMENARBEIT

Implemented by giz

aecid